# ជំពូក ៣


**យេនឌ័រមិនមែនជាបញ្ហាជីវសាស្ត្រនោះទេ** ............ 42

**សកម្មភាព៖** តួនាទីភេទ និងតួនាទីយេនឌ័រ៖ តើខុសគ្នាត្រង់ណា? ............ 42

ការពិចារណាលើភាពជាបុរស និងភាពជាស្ត្រី ............ 44

**សកម្មភាព៖** ប្រអប់យេនឌ័រ ............ 44

**សកម្មភាព៖** ចុះប្រសិនបើគ្មានប្រអប់យេនឌ័រវិញ? ............ 46

យេនឌ័រ និងការងារ ............ 48

**សកម្មភាព៖** ការងារក្នុងមួយថ្ងៃ ............ 48

តួនាទីយេនឌ័រ តែងតែប្រែប្រួលទៅតាមពេលវេលា ............ 50

**សកម្មភាព៖** ជីវិតកាលពីអតីតកាល ............ 51

**យេនឌ័រ អំណាច និងសុខភាព** ............ 52

**សកម្មភាព៖** តុល្យភាពនៃបន្ទុក ............ 54

**សកម្មភាព៖** ល្បែងកម្សាន្តដូមីណូ ............ 56

**ការប្រាស្រ័យទាក់ទងជាទម្រង់មួយនៃអំណាច** ............ 58

**សកម្មភាព៖** របៀបនិយាយដោយប្រើពាក្យ "ខ្ញុំ" ............ 59

**ក្រុមបុរសដែលធ្វើការងារដើម្បីសមភាពយេនឌ័រ** ............ 60

**សកម្មភាព៖** ល្ខោនកាយវិការ ............ 63

**ការចិញ្ចឹមកូនប្រុសនិងកូនស្រីដោយស្មើភាពគ្នា** ............ 64

ផ្លាស់ប្តូររបៀបបង្រៀនយេនឌ័រដល់ក្មេងប្រុសស្រី ............ 64

**សកម្មភាព៖** ការកែប្រែក្បួនច្បាប់ ............ 65

**សកម្មភាព៖** ការសម្រេចក្តីសុបិនរបស់អ្នក ............ 67

**សកម្មភាព៖** ពិភពនៃការផ្សព្វផ្សាយផលិតផល ៖ ស្ត្រីសិចស៊ី និងបុរសរឹងមាំ ............ 68

**ការប្រើប្រាស់ច្បាប់ដើម្បីយុត្តិធម៌យេនឌ័រ** ............ 70

ការផ្លាស់ប្តូរទាមទារភាពមោះមុតនិងពេលវេលា ............ 73




www.hesperian.org health guides

# យេនឌ័រ និងសុខភាព



ការស្វែងយល់អំពីយេនឌ័រ គឺជាផ្នែកមួយនៅក្នុងការស្វែងយល់ពីឆាកជីវិតរបស់យើងនោះដែរ។ កុមារតែងតែរៀនចេះពីវ័យក្មេងមកថារាងកាយខុសគ្នារវាងបុរសនិងស្ត្រី ធ្វើឲ្យពួកគេមានគំនិត អារម្មណ៍ និងអាកប្បកិរិយាខុសគ្នាដែរ។

តួនាទីនិងការរំពឹងទុកក្នុងយេនឌ័រ មានភាពខុសៗគ្នាទៅតាមសហគមន៍ អាស្រ័យលើទំនៀមទម្លាប់ ប្រពៃណី ច្បាប់ និងសាសនារបស់ពួកគេ។ នៅតំបន់ជាច្រើន ក្មេងប្រុសនិងបុរសមានឋានៈខ្ពស់ជាង។ ពួកគេមានសិទ្ធិមូលដ្ឋាន និងសិទ្ធិពិសេសមួយចំនួនដែលស្ត្រីមិនមាន។ នៅពេលដែលស្ត្រីមានឋានៈទាបជាងបុរសខ្លាំងពេក ពួកគេច្រើនតែទទួលរងនូវហិង្សា ទទួលបានការថែទាំសុខភាពតិចតួច និងមិនសូវមានអំណាចក្នុងការសម្រេចចិត្តអំពីសុខភាពរបស់ពួកគេទេ។ ហេតុដូច្នេះហើយ ការត្រិះរិះពិចារណាអំពីក្បួនច្បាប់យេនឌ័រ និងការធ្វើការងារដើម្បីសមភាពយេនឌ័រ គឺជាផ្នែកដ៏សំខាន់ក្នុងការទ្រទ្រង់សុខភាពរបស់ក្មេងស្រីនិងស្ត្រី។

ការផ្លាស់ប្តូរ គឺមិនងាយនឹងកើតឡើងឡើយ! មនុស្សខ្លះគាំទ្រតួនាទីយេនឌ័រដែលមិនស្មើភាពគ្នានេះ មានន័យថាពួកគេចង់រក្សាអ្វីៗឲ្យនៅដដែល។ អ្នកខ្លះទៀតអាចនឹងមិនគាំទ្រវិសមភាពយេនឌ័រ ប៉ុន្តែពួកគេគិតថាមិនអាចកែប្រែវាបានទេ គឺដូចជាបញ្ហាអាកាសធាតុដូច្នេះដែរ។ អ្នកពុំគួរបាត់បង់ទឹកចិត្តដោយសារពួកគេទេ។ អ្នកកំពុងតែចូលរួមជាមួយអ្នករៀបចំ អ្នកអប់រំសុខភាព និងអ្នកដទៃទៀតជាច្រើនដែលកំពុងតែប្រើប្រាស់អំណាចនិងភាពច្នៃប្រឌិតរបស់ខ្លួន ដើម្បីនាំមកនូវការផ្លាស់ប្តូរនានាដែលធានាឲ្យមានការកែលម្អសុខភាពរបស់ស្ត្រី។

# យេនឌ័រមិនមែនជាបញ្ហាជីវសាស្ត្រនោះទេ

នៅពេលទារកម្នាក់កើតមក គេសួរថា "តើជាស្រី ឬប្រុស?" អ្នកអាចមើលប្រដាប់ភេទរបស់ទារកនោះដើម្បីឆ្លើយសំណួរនេះ។ ទារកមានភេទស្រី បើគាត់មានយោនី ឬមានភេទប្រុស បើគាត់មានលិង្គ។ លក្ខណៈនៃភេទនេះ គឺជាផ្នែកមួយនៃជីវសាស្ត្រ។ ប៉ុន្តែយេនឌ័រ គឺខុសគ្នា។ វប្បធម៌ ទំនៀមទម្លាប់ និងច្បាប់របស់យើង បានកំណត់នូវតួនាទីយេនឌ័រសម្រាប់បុរសនិងស្ត្រី។ តួនាទីនេះចែងថា ស្ត្រីត្រូវធ្វើការងារផ្ទះ ហើយបុរសជាអ្នកសម្រេចចិត្តសំខាន់ៗនៅក្នុងសហគមន៍។ មនុស្សយើងច្រើនតែយល់ច្រឡំរវាងតួនាទីយេនឌ័រ ជាមួយនិងតួនាទីភេទ ហើយគិតថាវាជារឿងធម្មជាតិ ឬមិនអាចផ្លាស់ប្ដូរបាន។

ដើម្បីស្វែងយល់អំពីទំនាក់ទំនងរវាងយេនឌ័រនិងសុខភាព យើងត្រូវយល់ថាតើផ្នែកណាខ្លះរបស់បុរស/ស្ត្រី គឺជាជីវសាស្ត្រ ហើយតើផ្នែកណាខ្លះដែលកំណត់ដោយមនុស្ស។ ការដឹងពីភាពខុសគ្នានេះ អាចជួយឲ្យយើងសម្រេចថាតើយើងអាចផ្លាស់ប្ដូរអ្វីខ្លះ និងថាតើយើងគួរផ្ដោតការប្រឹងប្រែងទៅលើចំណុចណាខ្លះ ដើម្បីកែប្រែវិសមភាពរវាងបុរសនិងស្ត្រីនៅក្នុងសហគមន៍របស់យើង។

## សកម្មភាព — តួនាទីភេទ និងតួនាទីយេនឌ័រ ៖ តើខុសគ្នាត្រង់ណា?

1. បិតរូបភាពបុរសនិងស្ត្រីនៅលើផ្ទាំងក្រដាស២ ផ្សេងគ្នា។ ប្រាប់អ្នកចូលរួមឲ្យរកនឹកពាក្យមួយចំនួន ប្រសិនបើគាត់ឮពាក្យថា "បុរស" និង "ស្ត្រី" រួចសរសេរពាក្យទាំងនោះលើផ្ទាំងក្រដាស។ ប្រាប់ពួកគេឲ្យគិតអំពីរាងកាយ ចរិត សមត្ថភាព តួនាទីក្នុងគ្រួសារនិងសហគមន៍ ព្រមទាំងអំពីអារម្មណ៍និងឥរិយាបថដែលបុរសឬស្ត្រីគួរប្រកាន់យក។ បន្ទាប់មក អានពាក្យទាំងនោះឲ្យឮៗឲ្យក្រុមទាំងមូលស្ដាប់។



## សកម្មភាព — តួនាទីភេទ និងតួនាទីយេនឌ័រ ៖ តើខុសគ្នាត្រង់ណា? (ត)

2 ប្តូររូបស្ត្រី យកទៅបិតលើផ្ទាំងក្រដាសរបស់បុរស ហើយរូបបុរសមកបិតលើផ្ទាំងក្រដាសស្ត្រីវិញ។ សួរក្រុមថាតើពាក្យណាខ្លះនៅក្នុងបញ្ជីពាក្យរបស់បុរស ដែលមិនអាចរៀបរាប់លក្ខណៈរបស់ស្ត្រីបានជាដាច់ខាត ដូចជាពាក្យ "ឪពុក" ឬ "ពងស្វាស" ជាដើម។ គូសពាក្យទាំងនោះចោល។ ពន្យល់ថា រាល់ពាក្យដែលបានគូសចោល គឺសម្គាល់ថាជា "បុរសភេទ។ រីឯពាក្យដែលនៅសល់គឺជា "តួនាទីយេនឌ័រ" ដែលសង្គមរំពឹងថាបុរសគួរតែប្រកាន់ខ្ជាប់។

3 ធ្វើដូចគ្នាចំពោះបញ្ជីពាក្យរបស់ស្ត្រី។ គូសចោលលើពាក្យណាដែលមិនអាចរៀបរាប់លក្ខណៈរបស់បុរសបានជាដាច់ខាត ដូចជា "ការមករដូវ" និង "សម្រាលកូន។ ពាក្យដែលបានគូសចោល ពាក់ព័ន្ធនឹងរាងកាយរបស់ស្ត្រី ដូច្នេះវាសម្គាល់ថាជា "ស្ត្រីភេទ។ ពាក្យដែលនៅសល់គឺជា "តួនាទីយេនឌ័រ" របស់ស្ត្រី។

4 ពិភាក្សាពីភាពខុសគ្នារវាង "ភេទ" (ស្រី ឬប្រុស) និងតួនាទីយេនឌ័រ (ជាអ្វីដែលសង្គមគិតថាស្ត្រីនិងបុរសគួរមានរូបរាង អារម្មណ៍ គំនិត និងឥរិយាបថបែបណា)។ នេះជាសំណួរខ្លះៗ ៖

- ចូររៀបរាប់ពីភាពខុសគ្នារវាង ភេទ និង យេនឌ័រ។
- តើអ្នកយល់ស្របចំពោះគំនិតទាំងអស់ដែលបានរៀបរាប់ពីស្ត្រី និងគំនិតទាំងអស់ដែលបានរៀបរាប់ពីបុរសដែរឬទេ? តើមានគំនិតណាខ្លះដែលអ្នកមិនយល់ស្របតាម? ហេតុអ្វី?
- តើតួនាទីយេនឌ័រណាខ្លះដែលសង្គមច្រើនតែប្រើរួមគ្នារវាងបុរសនិងស្ត្រី?
- តើក្មេងប្រុសនិងក្មេងស្រី ស្វែងយល់ពីតួនាទីយេនឌ័ររបស់ខ្លួនយ៉ាងដូចម្តេច?

5 សួរក្រុមថា តើមានអ្វីខ្លះទៀតដែលអាចមានឥទ្ធិពលលើតួនាទីរបស់យេនឌ័រ ដូចជាអាយុ ការអប់រំ ពណ៌សម្បុរ ទ្រព្យសម្បត្តិ ឬអ្នកនោះស្ថិតក្នុងវណ្ណៈ ឬកុលសម្ព័ន្ធណាមួយ។ តើការរំពឹងទុករបស់យេនឌ័រ មានភាពខុសគ្នាបែបណា ចំពោះបុរសនិងស្ត្រីដែលមានឋានៈខ្ពស់ឬទាប? តើអ្នកណាមានអំណាចច្រើនជាងក្នុងការសម្រេចចិត្តដោយខ្លួនឯងនិងឲ្យអ្នកដទៃ? តើអ្នកណាមានសេរីភាពច្រើនជាងក្នុងការនិយាយស្តីនូវអ្វីដែលគេយល់ឃើញ, និងអាចធ្វើអ្វីមួយដែលខ្លួនយល់ថាល្អ?

6 ចុងក្រោយ ចូរពិភាក្សាថាតើភាពខុសគ្នានៃការរំពឹងទុករបស់យេនឌ័រ ធ្វើឲ្យប៉ះពាល់ដល់សុខភាពរបស់បុរសនិងស្ត្រីយ៉ាងដូចម្តេច។ តើតួនាទីនិងការរំពឹងទុកអ្វីខ្លះ ដែលធ្វើឲ្យបុរសឬស្ត្រីមានសុខភាពល្អ? តើការរំពឹងទុកអ្វីខ្លះដែលអាចបណ្តាលឲ្យស្ត្រីឬបុរសមានបញ្ហាសុខភាពកាន់តែច្រើន?

*ជួនកាលយើងគួរតែធ្វើការជាមួយក្រុមបុរស និងក្រុមស្ត្រីឲ្យដាច់ពីគ្នា ដើម្បីឲ្យពួកគេមានឱកាសនិយាយកាន់តែស្មោះត្រង់និងបើកចំហ។*



# ការពិចារណាលើភាពជាបុរស និងភាពជាស្ត្រី

តួនាទីយេនឌ័រ បង្កើតឲ្យមានការរំពឹងទុកផ្សេងៗនូវអ្វីដែលគេហៅថា "បុរសពេញលក្ខណៈ" និង "ស្ត្រីពេញលក្ខណៈ។ នៅពេលដែលការរំពឹងទុករបស់យេនឌ័រ មានរួមបញ្ចូលនូវការគោរពនិងការសរសើរចំពោះតួនាទីរបស់ភេទផ្សេងៗគ្នា នោះស្ត្រី និងបុរសអាចមានដំណើរជីវិតមួយដែលប្រកបទៅដោយភាពពេញចិត្ត ការរួមគ្នា និងសមិទ្ធិផលផ្សេង។ ប៉ុន្តែជារឿយៗ តួនាទីរបស់ស្ត្រី មានឋានៈទាបជាងយ៉ាងខ្លាំងធៀបនឹងតួនាទីរបស់បុរស។ ឋានៈមិនស្មើគ្នានៅក្នុងយេនឌ័រនេះ រឹតតែបណ្តាលឲ្យមានគ្រោះថ្នាក់ថែមទៀត នៅពេលដែលមានការរំពឹងទុកពីសង្គមថា បុរសមានការគ្រប់គ្រងលើស្ត្រីឬនរណាម្នាក់ដែលមានរូបរាងឬគំនិតដូចស្ត្រី។

វិធីមួយដើម្បីមើលឃើញពីភាពខុសគ្នារវាងឋានៈបុរសនិងស្ត្រី គឺតាមរយៈការឆ្លុះបញ្ចាំងពីបុគ្គលិកលក្ខណៈនៃភាពជាបុរសនិងភាពជាស្ត្រីដែលមនុស្សទូទៅកោតសរសើរ។ ធ្វើបែបនេះអាចជួយឲ្យមនុស្សគិតថាតើបុគ្គលិកលក្ខណៈណាខ្លះដែលសហគមន៍ទទួលស្គាល់ ហេតុអ្វី។ ការឆ្លុះបញ្ចាំងបែបនេះក៏ជួយឲ្យក្រុមស្វែងយល់ថាតើបុរសនិងស្ត្រីទូទៅប្រព្រឹត្តបែបណាដើម្បីលើកកម្ពស់ការរំពឹងទុកក្នុងយេនឌ័រ ហើយតើនឹងមានអ្វីកើតឡើងបើមនុស្សម្នាក់ប្រព្រឹត្តខុសគេ។

## សកម្មភាព ប្រអប់យេនឌ័រ

1. បំបែកក្រុមទៅជាក្រុមបុរស និងក្រុមស្ត្រី។ ចែកផ្ទាំងក្រដាសធំមួយដល់ក្រុមទាំង។

2. ប្រាប់ក្រុមនីមួយៗឲ្យគូររូបមនុស្សដែលស័ក្តិសមជាស្ត្រី ឬស័ក្តិសមជាបុរស ។ ពួកគេគួរគូររូបសម្លៀកបំពាក់សមរម្យ ហើយគូរបង្ហាញនូវសកម្មភាពដែល "ស្ត្រីស័ក្តិសម" ឬ "បុរសស័ក្តិសម" គួរធ្វើ។ ប្រាប់ពួកគេឲ្យគូរប្រអប់ធំព័ទ្ធជុំវិញរូបមនុស្សនោះ ។

3. បន្ទាប់មកប្រាប់ពួកគេឲ្យសរសេរឬគូររូបជុំវិញរូបមនុស្សនោះ នូវលក្ខណៈសម្បត្តិទាំងឡាយណាដែលស័ក្តិសមជាស្ត្រី ឬបុរស។ ប្រាប់ពួកគេឲ្យគិតថាតើបុរសនិងស្ត្រីគួរមានរូបរាងបែបណា និងគួរមានឥរិយាបថបែបណានៅក្នុងសង្គម ក្នុងការងារ ក្នុងគ្រួសារ និងក្នុងទំនាក់ទំនងផ្លូវភេទ។

   តើបុរសគួរមានសមត្ថភាពធ្វើអ្វីខ្លះ? តើស្ត្រីគួរមានសមត្ថភាពធ្វើអ្វីខ្លះ? តើអារម្មណ៍អ្វីខ្លះដែលបុរសអាចបង្ហាញចេញមកក្រៅបាន? អារម្មណ៍អ្វីខ្លះដែលស្ត្រីអាចបង្ហាញចេញមកក្រៅបាន?

4. បន្ទាប់មកប្រាប់ក្រុមទាំង២ឲ្យគិតពិចារណាអំពីបុគ្គលិកលក្ខណៈទាំងឡាយរបស់ស្ត្រីឬបុរស ប៉ុន្តែដែលមិនត្រូវបានគិតថាស័ក្តិសមទៅវិញ។ សរសេរពាក្យដែលរៀបរាប់ពីចំណុចស័ក្តិសមទាំងនោះនៅលើក្រដាស ខាងក្រៅប្រអប់។ អ្នកអាចសួរថា ៖ តើបុរសគួរលាក់ទុកនូវអារម្មណ៍អ្វីខ្លះ? រួចចុះស្ត្រី?



www.hesperian.org health guides

## សកម្មភាព ប្រអប់យេនឌ័រ (ត)




5. ឲ្យក្រុមទាំង២ចូលរួមគ្នាវិញ ហើយធ្វើការបង្ហាញនូវគំនូររបស់ខ្លួន។

6. ពិភាក្សាអំពីគំនូរនោះ និងការរំពឹងទុកនានាដែលមាន។ ឧទាហរណ៍ សួរថាតើបុរសស័ក្តិសម ឬស្ត្រីស័ក្តិសម អាចទទួលបានផលប្រយោជន៍ពីបុគ្គលិកលក្ខណៈឬសកម្មភាពនៅក្នុងប្រអប់យ៉ាងដូចម្តេចខ្លះ។ តើបុគ្គលិកលក្ខណៈឬសកម្មភាពណាខ្លះដែលត្រូវបានគិតថាខ្សោយ ឬមិនសូវសំខាន់? ហេតុអ្វី?

7. សួរក្រុមថាតើពួកគេគិតថាបុរសឬស្ត្រីភាគច្រើនពិបាកធ្វើបាននូវចំណុចស័ក្តិសមទាំងនេះមែនឬទេ? ហេតុអ្វី? តើមានអ្វីកើតឡើងចំពោះមនុស្សដែលមិនស្ថិតក្នុងប្រអប់ "ស័ក្តិសម" ឬចំពោះមនុស្សដែលព្យាយាមរស់នៅក្រៅប្រអប់ "ស័ក្តិសម"? តើការរស់នៅខុសពីគេ មានទាំងផលប្រយោជន៍ និងគុណវិបត្តិមែនឬទេ?តើមានដូចម្តេចខ្លះ? (អ្នកអាចកត់សម្គាល់ថា មនុស្សជាក់ស្តែងមានចំណុចនៅក្នុងប្រអប់ទាំង២)។ សួរក្រុមថា ៖ តើប្រអប់ទាំងនេះអាចប៉ះពាល់ដល់សុខភាពរបស់បុរសនិងស្ត្រីយ៉ាងដូចម្តេច?

8. បន្ទាប់មកសួរថា ៖ តើប្រអប់ទាំងនេះមានប្រភពចេញពីណា? តើមនុស្សបានរៀនសូត្រពី "ក្បួនច្បាប់" នៃការធ្វើជាក្មេងស្រី ក្មេងប្រុស ស្ត្រី ឬបុរស តាំងពីពេលណា? តើនរណាជាអ្នកបង្រៀនអំពីក្បួនច្បាប់ទាំងនេះ? តើក្បួនទាំងនេះចេញពីឪពុកម្តាយក្នុងកម្រិតណា? តើចេញពីអាជ្ញាធរដទៃទៀតដូចជាគ្រូបង្រៀន គ្រូបង្វឹក ឬអ្នកដឹកនាំសាសនា ក្នុងកម្រិតណាដែរ? តើចេញពីប្រព័ន្ធផ្សព្វផ្សាយ ដូចជាទូរទស្សន៍ ការផ្សព្វផ្សាយផលិតផល ភាពយន្ត ចម្រៀង និងវីដេអូក្នុងកម្រិតណាដែរ?

ដើម្បីបន្តស្វែងយល់អំពីតួនាទីយេនឌ័រជាមួយក្រុមស្ត្រី អ្នកអាចអនុវត្តសកម្មភាព "ចុះប្រសិនបើគ្មានប្រអប់យេនឌ័រវិញ?" (ទំព័រ 46)។

## ចូរស្រមៃពីពិភពលោកមួយដែលគ្មានប្រអប់យេនឌ័រ

ស្ត្រីច្រើនតែជជែកគ្នាស្ងាត់ៗអំពីបទពិសោធន៍និងអារម្មណ៍របស់ពួកគេ។ ការរៀបរាប់ពីភាពលំបាកផ្សេងៗក្នុងជីវិត ជាពិសេសអំពីការប្រាស្រ័យទាក់ទងដ៏លំបាកជាមួយបុរស ជួយឲ្យស្ត្រីមានអារម្មណ៍ថាមិនសូវឯកា។ ប៉ុន្តែការជជែកគ្នារបស់ពួកគេជាទូទៅមិនសូវលើកយកសំណួរដែលស្វែងរកមូលហេតុនៃភាពលំបាករបស់ពួកគេ ឬអំពីដំណោះស្រាយនៃបញ្ហានោះទេ។ សកម្មភាពឆ្លុះបញ្ចាំងនិងចែករំលែក អាចផ្ដល់នូវទីកន្លែងមួយដែលមានសុវត្ថិភាពនិងភាពងាយស្រួលដល់ស្ត្រី ដើម្បីឲ្យពួកគាត់ពិភាក្សាអំពីបទពិសោធន៍របស់ខ្លួន ព្រមទាំងប្រៀបធៀបតួនាទីរបស់ពួកគាត់ជាមួយនឹងតួនាទីរបស់បុរស។

សកម្មភាពនេះអាចធ្វើឡើងបន្ទាប់ពីសកម្មភាព "ប្រអប់យេនឌ័រ" ដើម្បីជួយឲ្យក្រុមធ្វើការពិចារណាថាតើតួនាទីយេនឌ័រ និងការរំពឹងទុកក្នុងយេនឌ័រ អាចផ្លាស់ប្ដូរយ៉ាងដូចម្ដេចដើម្បីឲ្យស្ត្រីទទួលបានសិទ្ធិបន្ថែមទៀតក្នុងការថែទាំសុខភាពរបស់ខ្លួន។

### សកម្មភាព — ចុះប្រសិនបើគ្មានប្រអប់យេនឌ័រវិញ?

អនុវត្តសកម្មភាពនេះជាមួយក្រុមស្ត្រីនិងក្មេងស្រី ដោយគ្មានវត្តមានបុរសឬក្មេងប្រុស។ (អ្នកអាចកែច្នៃសកម្មភាពនេះសម្រាប់ក្រុមបុរសនិងក្មេងប្រុសផងដែរ)។ បង្ហាញពួកគេនូវរូបភាពប្រអប់យេនឌ័រដែលបានគូរនៅក្នុងសកម្មភាពនៅទំព័រ 44-45 ។ ពន្យល់ក្រុមថា សកម្មភាពនេះអាចជួយយើងឲ្យពិចារណាថាតើអ្វីៗអាចប្រែប្រួលយ៉ាងដូចម្ដេច មានន័យថាតើមានអ្វីកើតឡើងប្រសិនបើគ្មានប្រអប់យេនឌ័រទាល់តែសោះនោះ?

1 **ការឆ្លុះបញ្ចាំងដោយមានការណែនាំ។** ដើម្បីធ្វើឲ្យសកម្មភាពនេះមានលក្ខណៈដូចស្ថានភាពពិត គឺមិនដូចជាការប្រជុំ ចូរប្រាប់ក្រុមស្ត្រីឲ្យអង្គុយជារង្វង់។ អ្នកអាចបិទភ្លើងខ្លះ ឲ្យបន្ទប់ងងឹត ឬចាក់ចម្រៀងតិចៗ។ ប្រាប់ក្រុមស្ត្រីឲ្យបិទភ្នែក ដកដង្ហើមវែងៗ រួចស្រមៃថាខ្លួនគឺជាក្មេងស្រីតូចម្នាក់។ ពន្យល់ថា ដំបូងអ្នកសុំឲ្យពួកគេចងចាំ បន្ទាប់មកទើបធ្វើការស្រមើស្រមៃ។ ស្ត្រីគ្រាន់តែគិតប៉ុណ្ណោះ មិនឲ្យនិយាយចេញមកទេ, នេះជាលំហាត់ស្ងៀមស្ងាត់។

និយាយមួយៗនិងទន់ភ្លន់ ហើយសួរសំណួរដូចខាងក្រោម ៖

- តើអ្នកចាប់ផ្ដើមដឹងថាក្មេងស្រីខុសពីក្មេងប្រុស នៅពេលណា? តើអ្នកដឹងដោយរបៀបណា ហើយពេលនោះអ្នកមានអារម្មណ៍បែបណា?
- ប្រសិនបើក្មេងស្រីនិងក្មេងប្រុសត្រូវបានចិញ្ចឹមបីបាច់ដោយស្មើភាពគ្នា តើជីវិតជាក្មេងស្រីគួរតែខុសគ្នានឹងសភាពបច្ចុប្បន្នដូចម្ដេចខ្លះ? ប្រសិនបើពួកគេមានសេរីភាព និងការទទួលខុសត្រូវដូចៗគ្នា?
- តើបុរសនឹងទៅជាយ៉ាងណាបើមានសេរីភាពបន្ថែមទៀត? តើជីវិតរបស់បុរសនឹងប្រែប្រួលយ៉ាងដូចម្ដេច ប្រសិនបើតួនាទីនិងការទទួលខុសត្រូវរបស់ពួកគេ មានស្មើគ្នាដូចនឹងស្ត្រីដែរ?
- តើស្ត្រីនឹងទៅជាយ៉ាងណាបើមានសេរីភាពបន្ថែមទៀត? តើជីវិតរបស់ស្ត្រីនឹងប្រែប្រួលយ៉ាងដូចម្ដេច ប្រសិនបើតួនាទីនិងការទទួលខុសត្រូវរបស់ពួកគេ មានស្មើគ្នាដូចនឹងបុរសដែរ?

រង់ចាំមួយឬពីរនាទីបន្ទាប់ពីសំណួរនីមួយៗ ដើម្បីឲ្យស្ត្រីគ្រប់គ្នាមានពេលវេលាគ្រប់គ្រាន់ក្នុងការត្រិះរិះពិចារណា។

## សកម្មភាព ចុះប្រសិនបើគ្មានប្រអប់យេនឌ័រវិញ? (ត)

❷ **ឲ្យពួកគេចែករំលែកគំនិតជាមួយគ្នាក្នុងក្រុមតូចៗ។** ប្រាប់ស្ត្រីគ្រប់គ្នាឲ្យបើកភ្នែក ហើយឲ្យពួកគេបែងចែកជាក្រុមតូចៗ ដើម្បីចែករំលែកនូវគំនិតរបស់ខ្លួន។ ស្ត្រីទាំងអស់គួរទទួលបានពេលវេលាគ្រប់គ្រាន់ដើម្បីនិយាយ ហើយស្ត្រីដទៃទៀតគួរស្តាប់យ៉ាងស្ងៀមស្ងាត់។

❸ **ការស្រមៃអំពីពិភពលោកមួយដែលគ្មានប្រអប់យេនឌ័រ។** បន្ទាប់ពីស្ត្រីគ្រប់គ្នាបានចែករំលែកនូវគំនិតរបស់ខ្លួនរួចរាល់ហើយ ចូរប្រាប់ពួកគេឲ្យស្ថិតនៅក្នុងក្រុមតូចៗដដែលនោះ រួចពិភាក្សាលើសំណួរខាងក្រោម៖

- ប្រសិនបើស្ត្រីនិងបុរសទទួលបានការយកចិត្តទុកដាក់ប្រហែលគ្នា តើស្ត្រីនឹងមានឥរិយាបថខុសពីបច្ចុប្បន្នដូចម្តេច? តើពួកគេនឹងមានអារម្មណ៍បែបណា?
- ប្រសិនបើស្ត្រីមានសេរីភាព អំណាច និងការទទួលខុសត្រូវដូចគ្នានឹងបុរសដែរ តើស្ត្រីនឹងមានឥរិយាបថដូចម្តេច? តើពួកគេនឹងមានអារម្មណ៍បែបណា?
- តើក្មេងប្រុសនិងបុរសនឹងមានឥរិយាបថនិងអារម្មណ៍បែបណា?
- តើជីវិតរបស់អ្នកផ្ទាល់ នឹងមានភាពប្រែប្រួលដូចម្តេច? តើជីវិតនឹងមានភាពប្រែប្រួលដូចម្តេចខ្លះសម្រាប់ស្ត្រីដទៃដែលអ្នកស្គាល់? សម្រាប់កូនស្រីរបស់អ្នក? សម្រាប់ម្តាយរបស់អ្នក?

❹ **ការគូររូបដោយមិនមានប្រអប់។** អ្នកក៏អាចស្នើសុំឲ្យក្រុមគូររូបជាថ្មីផងដែរ ថាតើជីវិតនឹងទៅជាយ៉ាងណាប្រសិនបើគ្មានប្រអប់យេនឌ័រ។ ចែកផ្ទាំងក្រដាសធំមួយដល់ក្រុមទាំងអស់ ហើយប្រាប់ពួកគេឲ្យគូររូបស្ត្រីដែលស័ក្តិសមម្នាក់នៅក្នុងពិភពលោកមួយដែលពួកគាត់មានសេរីភាព អំណាច ការរំពឹងទុក និងការទទួលខុសត្រូវដូចបុរសដែរ។ អ្នកអាចសុំឲ្យពួកគេគូររូបបុរសដែលស័ក្តិសមផងដែរ។







❺ ដើម្បីបញ្ចប់សកម្មភាពនេះ ចូរស្នើសុំឲ្យក្រុមទាំងអស់ចែករំលែកនូវចក្ខុវិស័យ និងគំនូររបស់ពួកគេ។ អ្នកក៏អាចសួរពួកគេឲ្យឆ្លើយថាតើសុខភាពនឹងមានភាពប្រែប្រួលដូចម្តេចសម្រាប់ស្ត្រីនិងក្មេងស្រី ហើយសម្រាប់បុរសនិងក្មេងប្រុស។ ត្រូវប្រាកដថា អ្នកចូលរួមមានពេលវេលាគ្រប់គ្រាន់ដើម្បីចែករំលែកនូវអារម្មណ៍របស់ពួកគេ ហើយសួរថា បន្ទាប់ពីបានពិភាក្សានិងគូររូបរួចមក តើពួកគេកំពុងគិតអំពីអ្វី។

# យេនឌ័រ និងការងារ

នៅគ្រប់សហគមន៍ទាំងអស់ មានការងារខ្លះត្រូវបានចាត់ទុកថាជា "ការងារបុរស" ហើយការងារខ្លះទៀតជា "ការងារស្ត្រី។ ភាពខុសគ្នានៃការរំពឹងទុកទាំងនេះ គឺជាផ្នែកមួយនៃតួនាទីយេនឌ័រ។

ការងារដែលស្ត្រីជាច្រើនធ្វើ ដូចជាមើលថែកូន និងតម្រូវការប្រចាំថ្ងៃរបស់គ្រួសារ ច្រើនតែមិនទទួលបានតម្លៃខ្ពស់ទេ ឬថែមទាំងមិនត្រូវបានគិតថាជាការងារទៀតផង។ នេះគឺជាមូលហេតុមួយដែលធ្វើឲ្យស្ត្រីមានឋានៈទាប និងមានការងារច្រើនដែលមិនស្មើភាព។ ការពិភាក្សាអំពីតួនាទីយេនឌ័រនិងការងារ អាចជួយឲ្យមនុស្សគិតអំពីការផ្លាស់ប្តូរផ្សេងៗដែលអាចនាំឲ្យសុខភាពរបស់ស្ត្រីបានប្រសើរឡើង។




**សកម្មភាព** **ការងារក្នុងមួយថ្ងៃ**

ការរៀបរាប់អំពីសកម្មភាពទាំងឡាយដែលបុរសនិងស្ត្រីធ្វើរៀងរាល់ថ្ងៃ អាចផ្តល់ជាមូលដ្ឋានសម្រាប់ការពិភាក្សាអំពីការងារ និងយេនឌ័រ។ ជួនកាលបុរស (ឬស្ត្រី) មិនបានដឹងទេថា តើស្ត្រី(ឬបុរស)ធ្វើអ្វីខ្លះក្នុងមួយថ្ងៃ។ អ្នកអាចកែច្នៃសកម្មភាពនេះដើម្បីយកប្រើជាមួយក្រុមដែលមានតែស្ត្រី ដើម្បីបង្កើនការយល់ដឹងរបស់ពួកគេ ថាការងារផ្ទះគឺជាការងារដែលមានតម្លៃដែរ។

1. បែងចែកអ្នកចូលរួមទាំងអស់ជាក្រុមតូចៗដែលមានតែបុរស ឬតែស្ត្រី។ ប្រាប់ក្រុមបុរសឲ្យរៀបរាប់ការងារទាំងឡាយដែលបុរសទូទៅធ្វើជារៀងរាល់ថ្ងៃ, ដោយគិតចាប់ពីពេលគាត់ក្រោកពីដេក រហូតដល់គាត់ចូលដេកវិញ។ ប្រាប់ក្រុមស្ត្រីឲ្យធ្វើដូចក្រុមបុរសដែរ។ អ្នកក៏អាចប្រាប់ពួកគេឲ្យគិតអំពីរយៈពេលដែលការងារនីមួយៗត្រូវការ ទីកន្លែងដែលការងារនោះកើតឡើង ហើយនរណាដែលជួយពួកគេក្នុងការងារនោះ។
2. បន្ទាប់ពីរៀបរាប់ការងាររបស់ខ្លួនអស់ហើយ ចូរឲ្យពួកគេរៀបរាប់ពីការងារដែលមនុស្សក្នុងភេទផ្ទុយពីខ្លួន ធ្វើជារៀងរាល់ថ្ងៃផងដែរ។ មានន័យថាបុរសរៀបរាប់ពីការងាររបស់ស្ត្រី ហើយស្ត្រីរៀបរាប់ពីការងាររបស់បុរស។
3. នៅពេលសរសេររួចរាល់អស់ហើយ ឲ្យពួកគេចែករំលែកគ្នានៅក្នុងក្រុមធំទាំងមូល។


www.hesperian.org health guides

## សកម្មភាព ការងារក្នុងមួយថ្ងៃ (ត)

4 ពិភាក្សាដោយធ្វើតារាងការងារ។ អ្នកអាចសួរពួកគាត់ថាតើមានការភ្ញាក់ផ្អើលដែរឬទេចំពោះការងារដែលបានរៀបរាប់ទាំងនេះ។ តើពួកគេគិតថាស្ត្រីបានរៀបរាប់ពីការងាររបស់បុរស បានល្អដែរឬទេ? តើបុរសបានរៀបរាប់ពីការងាររបស់ស្ត្រី បានល្អឬទេ?

5 ពិភាក្សាពីអ្វីដែលមាននៅក្នុងតារាងការងារ។ តើមានអ្វីខុសគ្នាចំពោះការងារបុរសនិងការងារស្ត្រី? ហេតុអ្វីបានជាបុរសនិងស្ត្រីធ្វើកាងារខុសគ្នា? តើការងារណាខ្លះរបស់បុរស ដែលស្ត្រីក៏អាចធ្វើបានល្អដែរ? តើការងារណាខ្លះរបស់ស្ត្រី ដែលបុរសក៏អាចធ្វើបានល្អដូចគ្នា? ហេតុអ្វីអាច ហេតុអ្វីមិនអាច?

6 ពិភាក្សាពីចំណុចខុសគ្នាដទៃទៀតអំពីការងាររបស់បុរសនិងស្ត្រី។ ឧទាហរណ៍ ចូរសួរថា តើក្រុមមួយណាមានពេលលំហែច្រើនជាង។ តើក្រុមមួយណាមានចំនួនការងារច្រើនជាង? តើពួកគេគិតថាភាពខុសគ្នាទាំងនេះ សមហេតុផលដែរឬទេ? ហេតុអ្វីសម ហេតុអ្វីមិនសម?

អ្នកអាចសួរថាតើបុរសឬស្ត្រីណាខ្លះដែលធ្វើការងារមួយចំនួនរបស់អ្នកមានភេទផ្ទុយពីខ្លួន (បុរសធ្វើការងារស្ត្រី ឬស្ត្រីធ្វើការងារបុរស)។ ហេតុអ្វីអ្នកទាំងនេះធ្វើការងារដែលគេរំពឹងថាជារបស់អ្នកដែលមានភេទផ្ទុយពីគាត់ទៅវិញ? តើពួកគេទទួលបានការគោរពថយចុះ ឬក៏កើនឡើងដែរឬទេ នៅពេលធ្វើការងារទាំងនោះ?

7 ដើម្បីបញ្ចប់សកម្មភាពនេះ សួរក្រុមថាតើពួកគេចង់ផ្លាស់ប្តូរការរំពឹងទុកណាមួយនៃការងារប្រចាំថ្ងៃរបស់បុរសនិងស្ត្រីដែរឬទេ។ សួរពួកគេថាតើការផ្លាស់ប្តូរនោះ អាចផ្តល់ប្រយោជន៍ដល់ស្ត្រីនិងបុរសដូចម្តេចខ្លះ ហើយនឹងមានឧបសគ្គអ្វីខ្លះ។ ពិភាក្សាថាតើមនុស្សម្នាក់ៗអាចធ្វើអ្វីខ្លះដើម្បីឲ្យការផ្លាស់ប្តូរនោះកើតឡើងបាន និងថាតើក្រុមទាំងមូលអាចធ្វើអ្វីខ្លះដើម្បីជួយឲ្យសហគមន៍ទាំងមូលធ្វើការផ្លាស់ប្តូរ។



### អង្គការ "អំបោះក្រហម" ជួយឱ្យស្ត្រីក្នុងប្រទេសគូយ៉ាណា រួមសាមគ្គីគ្នាដើម្បីទាមទារសិទ្ធិនិងសុខមាលភាព

នៅប្រទេសគូយ៉ាណា (Guyana) ក្នុងទ្វីបអាមេរិកខាងត្បូង មានជនជាតិជាច្រើនក្រុមផ្សេងៗដែលមានទំនៀមទម្លាប់ខុសៗគ្នា។ ក្រុមមួយមានដើមកំណើតភាគច្រើនមកពីអាហ្វ្រិកដែលត្រូវបាននាំមកក្នុងឋានៈជាទាសករ, ក្រុមមួយទៀតធ្វើចំណាកស្រុកពីឥណ្ឌា, ហើយក្រុមទីបីភាគច្រើនជាជនជាតិដើមគូយ៉ាណា។ ជាច្រើនឆ្នាំកន្លងមក ក្រុមជនជាតិទាំងនេះ មិនសូវសុខនឹងគ្នាទេ ហើយស្ត្រីមិនគិតថាពួកគេមានអ្វីដែលដូចគ្នាឡើយ។ អង្គការមួយដែលមានឈ្មោះថា "អំបោះក្រហម" (Red Thread) មានបំណងស្វែងរកវិធីផ្សះផ្សារស្ត្រីនៅក្នុងក្រុមទាំងនេះ ដើម្បីរួបរួមគ្នាលើកកម្ពស់ឋានៈរបស់ស្ត្រីគូយ៉ាណាទាំងអស់។ អង្គការអំបោះក្រហម បានធ្វើការស្ទាបស្ទង់មតិមួយដើម្បីស្វែងយល់ពីរបៀបដែលស្ត្រីប្រើប្រាស់ពេលវេលារបស់ពួកគាត់។ សមាជិកអង្គការអំបោះក្រហម បានចុះទៅជួបស្ត្រីនៅតាមផ្ទះ នៅទូទាំងប្រទេស ហើយធ្វើសម្ភាសន៍អំពីការងារដែលស្ត្រីធ្វើពេញមួយថ្ងៃ។ ពួកគេរកឃើញថា ស្ត្រីភាគច្រើនមានការងារស្រដៀងគ្នា ៖ ក្រោកពីព្រលឹម ដងទឹក ចម្អិនអាហារ បញ្ចុកកូន សម្អាតផ្ទះ ធ្វើដំណាំបន្លែ មានការងារទទួលកម្រៃ បោកគក់ មើលថែកូន និងការងារជាច្រើនផ្សេងទៀត។ ស្ទើរតែគ្រប់ស្ត្រីទាំងអស់ធ្វើការរយៈពេល១៥ ទៅ១៦ម៉ោងរៀងរាល់ថ្ងៃ។ អង្គការអំបោះក្រហមបានបង្ហាញលទ្ធផលនៃការស្ទង់មតិនេះទៅដល់ស្ត្រីទាំងនោះ រួចសួរថា "ហេតុអ្វីបានជាពួកយើងប្រកាន់ក្រុមឲ្យដាច់ដោយឡែកពីគ្នា? ពួកយើងទាំងអស់សុទ្ធតែធ្វើការងារដូចគ្នាទេតើ។ គម្រោងនេះគឺជាកិច្ចរួបរួមដ៏អស្ចារ្យមួយ។ អង្គការអំបោះក្រហមបានក្លាយទៅជាក្រុមស្ត្រីចម្រុះជនជាតិដ៏រឹងមាំមួយ ដែលធ្វើការជាច្រើនយ៉ាងដើម្បីលើកកម្ពស់សិទ្ធិស្ត្រី រួមមានការរកប្រាក់ចំណូល និងការបញ្ចប់ហិង្សាផ្អែកយេនឌ័រជាដើម។



# តួនាទីយេនឌ័រ តែងតែប្រែប្រួលទៅតាមពេលវេលា

ជាញឹកញាប់ តួនាទីយេនឌ័រតែងតែកំណត់ឋានៈស្ត្រីឲ្យនៅទាប ដែលមានន័យថាមិនសូវទទួលបានការថែទាំសុខភាព, មិនអាចគ្រប់គ្រងរាងកាយខ្លួនឯងយ៉ាងពេញលេញ, ធ្វើការងារច្រើនម៉ោង, និងមិនសូវមានអំណាចក្នុងការសម្រេចចិត្តទេ។ ដើម្បីឲ្យសហគមន៍អាចកែលម្អសុខភាពរបស់ស្ត្រីបាន ពួកគេចាំបាច់ត្រូវកែប្រែតួនាទីយេនឌ័រ ជាពិសេសចំណុចដែលធ្វើឲ្យស្ត្រីងាយរងគ្រោះពីបុរស។ ត្រង់នេះហាក់ដូចជាពិបាកកែប្រែខ្លាំងណាស់ ប៉ុន្តែវាមិនសូវជាពិបាកទេ នៅពេលដែលយើងយល់ដឹងថាយេនឌ័រមិនមែនជាបញ្ហាជីវសាស្ត្រនោះ, មានន័យថា អ្វីៗដែលយើងគិតថាស័ក្តិសមជាបុរស និងស័ក្តិសមជាស្ត្រី គឺជាការយល់ឃើញរបស់យើងតែប៉ុណ្ណោះ វាមិនមែនកើតចេញពីធម្មជាតិនោះទេ។ ម្យ៉ាងទៀតគួរចងចាំថា នៅគ្រប់តំបន់នៅទូទាំងសកលលោក តួនាទីយេនឌ័រតែងតែប្រែប្រួលទៅតាមពេលវេលា។ ការពិភាក្សាអំពីខ្សែជីវិតរបស់ស្ត្រីក្នុងអតីតកាល ធៀបនឹងបច្ចុប្បន្នកាល អាចជួយឲ្យមនុស្សមើលឃើញថាតួនាទីយេនឌ័រពិតជាផ្លាស់ប្តូរមែន និងឃើញថាការផ្លាស់ប្តូរទាំងនេះបានធ្វើឲ្យសុខភាពរបស់ស្ត្រីកាន់តែប្រសើរដូចម្តេចខ្លះ។

## សកម្មភាព៧ ជីវិតកាលពីអតីតកាល

នៅក្នុងសកម្មភាព "កែវចិញ្ចឹមត្រី" ស្ត្រីចំណាស់ៗអង្គុយជារង្វង់នៅខាងក្នុង រួចនិទានប្រាប់អំពីជីវិតរបស់ម្ដាយពួកគាត់កាលពីមុន។ ក្រុមស្ត្រីវ័យក្មេង អង្គុយជារង្វង់នៅខាងក្រៅ រួចស្ដាប់ ហើយសួរសំណួរនៅពេលក្រោយ។ បន្ទាប់ពីឆ្លើយសំណួររួច ក្រុមទាំង២ផ្លាស់ប្ដូរកន្លែងអង្គុយទៅវិញទៅមក រួចស្ត្រីវ័យក្មេងចែករំលែកនូវគំនិតរបស់ខ្លួនអំពីអ្វីទាំងឡាយដែលហាក់ដូចជាបានផ្លាស់ប្ដូរ រីឯស្ត្រីចំណាស់ជាអ្នកស្ដាប់វិញ។

1 ប្រាប់ស្ត្រីចំណាស់ឲ្យនិទានប្រាប់អំពីអ្វីដែលពួកគាត់បានចេះពីម្ដាយរបស់គាត់ ពាក់ព័ន្ធនឹងភាពជាស្ត្រី។ តើជីវិតរបស់គាត់ខុសគ្នាពីជីវិតរបស់ម្ដាយគាត់ដូចម្ដេចខ្លះ? តើមានការផ្លាស់ប្ដូរអ្វីខ្លះដែលធ្វើឲ្យជីវិតពួកគេខុសគ្នា? ហេតុអ្វីការផ្លាស់ប្ដូរទាំងនោះកើតឡើង?

សួរថាតើពួកគាត់ មិត្តភ័ក្តិ ឬម្ដាយរបស់គាត់ធ្លាប់បានតវ៉ាប្រឆាំងនឹងការរំពឹងទុករបស់សហគមន៍អំពីស្ត្រីភេទដែរឬទេ? តើធ្លាប់មានស្ត្រីដែលធ្វើខុសនឹងតួនាទីយេនឌ័រពីបុរាណដែរឬទេ? ពួកគាត់ធ្វើដូចម្ដេច? តើមានរឿងអ្វីកើតឡើងចំពោះពួកគាត់?

អ្នកក៏អាចស្នើសុំឲ្យពួកគេនិទានប្រាប់ស្ត្រីវ័យក្មេងអំពីការផ្លាស់ប្ដូរមួយចំនួនដែលពាក់ព័ន្ធនឹងទំនៀមទម្លាប់និងក្បួនច្បាប់ផ្សេងៗអំពីការសេពគប់គ្នានិងទំនាក់ទំនងបែបមនោសញ្ចេតនារវាងក្មេងប្រុសនិងក្មេងស្រី។ តើក្បួនច្បាប់ទាំងនេះបានផ្លាស់ប្ដូរដូចម្ដេចខ្លះទាក់ទិននឹងការចែចូវ ទំនាក់ទំនងផ្លូវភេទ និងការរៀបការ? តើកាលពីមុនស្ត្រីធ្វើអ្វីខ្លះដើម្បីថែទាំសុខភាពរបស់ខ្លួន?

2 នៅពេលដល់វេនរបស់ស្ត្រីវ័យក្មេង ប្រាប់ពួកគេឲ្យចាប់ផ្ដើមដោយការរៀបរាប់ប្រាប់ក្រុមថាតើនៅក្នុងភាពជាស្ត្រី តើពួកគេចូលចិត្តអ្វីខ្លះ។ តើការយល់ឃើញរបស់ពួកគេអំពីភាពជាស្ត្រី ខុសគ្នាពីការយល់ឃើញរបស់យាយពួកគេដូចម្ដេចខ្លះ? ហើយខុសពីការយល់ឃើញរបស់អ្នកដទៃក្នុងសហគមន៍ដូចម្ដេចខ្លះ?

ស្នើឲ្យពួកគេនិយាយអំពីគោលដៅអនាគតរបស់ខ្លួន។ តើស្ត្រីណាខ្លះដែលពួកគេកោតសរសើរ? ហេតុអ្វី? តើពួកគេសង្ឃឹមថានឹងទទួលបានអ្វីខ្លះពីដៃគូមនោសញ្ចេតនាឬស្វាមីរបស់ពួកគេ? តើពួកគេគិតថាជីវិតប្រកបដោយក្ដីសុខនៅថ្ងៃមុខ មានរូបរាងបែបណាខ្លះ?

3 ជាកិច្ចបញ្ចប់ ចូរសួរក្រុមទាំងមូលថាតើសកម្មភាពនេះបានបង្ហាញអ្វីខ្លះអំពីយេនឌ័រ និងថាតើវាបានផ្លាស់ប្ដូរដូចម្ដេចខ្លះ, និងថាតើពួកយើងអាចរួមចំណែកដូចម្ដេចខ្លះដើម្បីធ្វើឲ្យវាផ្លាស់ប្ដូរនៅក្នុងឆាកជីវិតរបស់យើងនេះ។

*ខ្ញុំបានធ្វើការជាមួយក្រុមក្មេងស្រីមួយក្រុមដែលមិនចង់ជួបជាមួយក្រុមស្ត្រីចំណាស់ទេ។ ផ្ទុយទៅវិញ ក្មេងស្រីទាំងនោះបានទៅធ្វើសម្ភាសន៍ជាមួយយាយរបស់ពួកគេ ឬជាមួយស្ត្រីផ្សេងទៀតដែលពួកគេស្គាល់។ ក្មេងស្រីអាចចែករំលែកនូវអ្វីដែលពួកគេបានរៀនទៅតាមរបៀបផ្សេងៗ។ ក្មេងស្រីខ្លះតែងកំណាព្យ ខ្លះទៀតសរសេរអត្ថបទដូចក្នុងទស្សនាវដ្ដី និងមានមួយចំនួនតូចប្រើប្រាស់ការសំដែងរឿង រួចដើរតួជាយាយរបស់ពួកគេ។*



# យេនឌ័រ អំណាច និងសុខភាព

បុគ្គលិកលក្ខណៈពីបុរាណមួយនៃភាពជាបុរស គឺការមានអំណាច ហើយជាទូទៅនៅក្នុងសហគមន៍មួយ តំណែងដែលមានអំណាចធំបំផុតត្រូវបានកាន់កាប់ដោយបុរស។ ឧទាហរណ៍ អ្នកដឹកនាំសហគមន៍ និងមន្ត្រីរដ្ឋាភិបាល ភាគច្រើនជាបុរស។ ជាញឹកញាប់បុរសធ្វើការសម្រេចចិត្តដោយមិនប្រឹក្សាជាមួយស្ត្រីទេ ឬសម្រេចចិត្តដោយមិនគិតពីផលប៉ះពាល់លើស្ត្រីឡើយ។ នៅក្នុងគ្រួសារមួយ ជាធម្មតាគេរំពឹងថាបុរសគឺជាអ្នកដឹកនាំគ្រួសារ និងជាអ្នកសម្រេចពីវិធីរកប្រាក់និងការចំណាយប្រាក់។ ក្នុងជីវិតប្តីប្រពន្ធ ជាញឹកញាប់បុរសច្រើនតែជាអ្នកសម្រេចថាតើការរួមភេទ ឬការប្រើប្រាស់ផែនការគ្រួសារ គួរធ្វើឡើងនៅពេលណានិងបែបណា។ វិសមភាពអំណាចទាំងនេះ គឺជាឫសគល់នៃបញ្ហាសុខភាពជាច្រើនដែលកើតឡើងញឹកញាប់ចំពោះស្ត្រី។

មនុស្សស្ទើរតែគ្រប់ៗគ្នាសុទ្ធតែមានអំណាចខ្លះ។ បញ្ហាគឺថាតើអំណាចនោះត្រូវបានបែងចែកនិងប្រើប្រាស់យ៉ាងដូចម្តេច។ ការពិភាក្សាអំពីប្រភេទផ្សេងៗនៃអំណាច អាចជួយឲ្យមនុស្សស្វែងយល់ថាតើគេអាចប្រើប្រាស់អំណាចក្នុងវិធីល្អ ឬវិធីគ្រោះថ្នាក់ដូចម្តេចខ្លះ។

**"អំណាចលើអ្វីមួយ"** គឺជាប្រភេទអំណាចដែលមានគ្រោះថ្នាក់បំផុត។ ជាទូទៅអំណាចប្រភេទនេះមានដូចជាការគំរាមកំហែង ការចាត់ចែងព្រឹត្តិការណ៍អ្វីមួយ ការប្រើហិង្សា ឬទណ្ឌកម្មដើម្បីបង្ខំមនុស្សម្នាក់ឬមួយក្រុមឲ្យធ្វើអ្វីមួយដែលពួកគេមិនពេញចិត្ត។




ជាញឹកញាប់ ជនមានអំណាចខ្លាំងប្រើបទបញ្ញត្តិ ទំនៀមទម្លាប់ និងច្បាប់ផ្សេងៗដើម្បីរក្សាអំណាចរបស់ខ្លួន និងដើម្បីគ្រប់គ្រងមនុស្សដទៃ ព្រមទាំងសកម្មភាពរបស់ពួកគេ។ អ្នកមានអំណាចតិច ដូចជាស្ត្រីជាដើម ជាធម្មតាត្រូវបានផ្តាច់ចេញពីការប្រើប្រាស់បទបញ្ញត្តិ ទំនៀមទម្លាប់ និងច្បាប់ដែលគ្រប់គ្រងជីវិតរបស់ពួកគេ រួមទាំងការទទួលបានសេវាថែទាំសុខភាពជាដើម។ ការប្រើអំណាចតាមរបៀបនេះ ជួនកាលហៅថា ការគាបសង្កត់។

អំណាចប្រភេទនេះអាចមានឥទ្ធិពលយ៉ាងខ្លាំងក្លា និងបន្តយ៉ាងយូរអង្វែង ដែលធ្វើឲ្យជនមានអំណាចតិច ទទួលយកថា វិសមភាពគឺជារឿងធម្មតា។ នៅពេលដែលរឿងបែបនេះកើតឡើង ពួកគេប្រហែលជាមិនជឿឡើយថាខ្លួននៅមានជម្រើស ឬមានឱកាសធ្វើការផ្លាស់ប្តូរនោះឡើយ ហើយអាចនឹងបញ្ជូនទស្សនៈនេះបន្តទៅឲ្យអ្នកដទៃទៀតផង។





**"អំណាចពីខាងក្នុង"** គឺជាលទ្ធភាពសម្តែងចេញនូវអារម្មណ៍និងគំនិតរបស់ខ្លួន។ អំណាចប្រភេទនេះ អនុញ្ញាតឲ្យមនុស្សធ្វើការស្រមើស្រមៃអំពីគោលដៅមួយ និងជឿជាក់ថាពួកគេអាចដើរទៅដល់គោលដៅនោះ។ ក្មេងស្រីនិងស្ត្រីនៅទូទាំងពិភពលោកបានបង្ហាញឲ្យឃើញនូវអំណាចប្រភេទនេះ នៅពេលពួកគេជម្នះបន្តការសិក្សា បើទោះជាមានឧបសគ្គយ៉ាងណាក៏ដោយ, រក្សាក្រុមគ្រួសារឲ្យគង់វង្សក្នុងស្ថានភាពលំបាក, និងរិះរកវិធីការពារសុខភាពរបស់ខ្លួន របស់គ្រួសារ និងសហគមន៍។




**"អំណាចរួម"** គឺអាចទទួលបានតាមរយៈការសាមគ្គីជាមួយអ្នកដទៃទៀតនៅក្នុងសហគមន៍ តាមរយៈការរួបរួមគ្នា និងការសហការគ្នា។ អំណាចរួម ធ្វើឲ្យលទ្ធភាពរបស់មនុស្សកាន់តែរឹងមាំ ហើយអាចធ្វើការងារដើម្បីការផ្លាស់ប្តូរផ្សេងៗដែលនាំមកនូវកិត្តិយស ភាពយុត្តិធម៌ និងសុខភាពសម្រាប់មនុស្សគ្រប់រូបក្នុងសហគមន៍ទាំងមូល។

ដើម្បីស្វែងយល់បន្ថែមអំពីប្រភេទផ្សេងៗនៃអំណាច សូមមើលសកម្មភាព "អំណាចខ្លាំង និង អំណាចតិច" (ទំព័រ 154)។

## ស្វែងយល់ពីទំនាក់ទំនងរវាង ៖ តួនាទីយេនឌ័រ អំណាច និងសុខភាព

សកម្មភាពនៅ៤ទំព័របន្ទាប់ទៀតនេះ អាចជួយឲ្យក្រុមធ្វើការស្វែងយល់ពីការរំពឹងទុកក្នុងយេនឌ័រ វិសមភាពអំណាច និងថាតើបញ្ហាទាំង២នេះប៉ះពាល់ដល់សុខភាពរបស់ស្ត្រីដូចម្តេចខ្លះ។ សកម្មភាពទាំងនេះអាចត្រូវបានអនុវត្តជាមួយគ្នា ឬដាច់ដោយឡែកពីគ្នា ដើម្បីស្វែងយល់ពីទំនាក់ទំនងរវាងតួនាទីយេនឌ័រ អំណាច និងសុខភាព។ អ្នកក៏អាចកែច្នៃសកម្មភាពទាំងនេះដើម្បីពិនិត្យមើលទៅលើបញ្ហាជាក់លាក់ណាមួយពាក់ព័ន្ធនឹងសុខភាពរបស់ស្ត្រី ដូចជាការសម្រាលកូនដោយសុវត្ថិភាព បន្ទាប់មកពិភាក្សាថាតើតួនាទីយេនឌ័រ និងអំណាច ប៉ះពាល់ដល់បញ្ហានេះដូចម្តេចខ្លះ។

**សកម្មភាព** 

## តុល្យភាពនៃបន្ទុក




សកម្មភាពនេះអាចជួយឲ្យក្រុមស្វែងយល់ថាតើភាពខុសគ្នារវាងអំណាច និងការរំពឹងទុកពីបុរសនិងស្ត្រី ធ្វើឲ្យមានវិសមភាពនៃបន្ទុកដែលប៉ះពាល់ដល់សុខភាពរបស់ស្ត្រីដូចម្តេចខ្លះ។ អ្នកអាចអនុវត្តសកម្មភាពនេះជាមួយក្រុមដែលមានតែស្ត្រីនិងក្មេងស្រី ឬរួមជាមួយក្រុមបុរសដែលផ្តល់ការគាំទ្រ។ ដើម្បីរៀបចំ ៖ ចងកំប៉ុង២ឲ្យស្មើគ្នានៅលើកំណាត់ឈើមួយ។ កំប៉ុងមួយជាបន្ទុករបស់ស្ត្រី ហើយមួយទៀតរបស់បុរស។ ត្រៀមសណ្តែកឬដុំគ្រួសសម្រាប់ដាក់ក្នុងកំប៉ុង។ ម្យ៉ាងទៀត ត្រៀមក្រដាសមួយចំនួនផងដែរ។

1. និទានរឿងរបស់វណ្ណា អំពីការមានផ្ទៃពោះគ្មានសុវត្ថិភាព (ទំព័រ 222) ឬសាច់រឿងរបស់អ៊ីម៉ា អំពីការរួមភេទ និងកូនក្រមុំដែលមិនសប្បាយចិត្ត (ទំព័រ 95) ដើម្បីជួយឲ្យក្រុមគិតថាតើវិសមភាពយេនឌ័រប៉ះពាល់ដល់សុខភាពរបស់ស្ត្រីយ៉ាងដូចម្តេច។

2. ប្រាប់ក្រុមឲ្យពិចារណានូវសាច់រឿងនេះ ព្រមទាំងពីជីវិតនិងបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ។ ប្រាប់ពួកគេឲ្យពិចារណាពីឧទាហរណ៍ដែលការរំពឹងទុកក្នុងយេនឌ័រ អាចរារាំងស្ត្រីឬបុរសមិនឲ្យប្រព្រឹត្តិឥរិយាបទដែលការពារសុខភាពរបស់ស្ត្រីបាន។ ការរារាំងទាំងនេះ អាចត្រូវបានចាត់ទុកថាជាបន្ទុកដែលកំណត់ដោយការរំពឹងទុកក្នុងយេនឌ័រ។

3. ប្រាប់ពួកគេឲ្យផ្តល់ឧទាហរណ៍អំពី "បន្ទុក", ពោលគឺ តួនាទីយេនឌ័រ ឬការរំពឹងទុកផ្សេងៗក្នុងយេនឌ័រ ដែលប៉ះពាល់ដល់សុខភាពរបស់ស្ត្រី។ នៅពេលមនុស្សម្នាក់រៀបរាប់ពីបន្ទុកមួយ ចូរប្រាប់គាត់ឲ្យយកសណ្តែកមួយគ្រាប់ទៅដាក់ក្នុងកំប៉ុងរបស់ស្ត្រី ឬរបស់បុរសទៅតាមឧទាហរណ៍។ ចំពោះឧទាហរណ៍ដែលប៉ះពាល់ខ្លាំងដល់សុខភាពរបស់ស្ត្រី ចូរបន្ថែមគ្រាប់សណ្តែកថែមទៀត។ ប្រសិនបើបន្ទុកនោះរឹតតែមានគ្រោះថ្នាក់ចំពោះក្មេងស្រី ជនចំណាកស្រុក ឬក្រុមជនជាតិភាគតិច ចូរបន្ថែមគ្រាប់សណ្តែកផងដែរ។

សរសេរបន្ទុកនោះនៅលើក្រដាស រួចបិតលើជញ្ជាំង ដោយបែងចែកម្ខាងសម្រាប់បុរស និងម្ខាងសម្រាប់ស្ត្រី។ គួរកត់សម្គាល់ថា បន្ទុករបស់ស្ត្រីភាគច្រើនគឺបណ្តាលមកពីមិនមានអំណាច ឬមិនអាចប្រើប្រាស់ប្រាក់និងធនធាន។


www.hesperian.org health guides

**សកម្មភាព** តុល្យភាពនៃបន្ទុក (ត)




4 ប្រាប់ក្រុមឲ្យក្រឡេកទៅមើលអម្រែក ហើយសួរថាតើកំប៉ុងមួយណាមានបន្ទុកច្រើនជាង។ ពន្យល់ថា តាមរយៈការពិភាក្សាពីវិសមភាពទាំងនេះ គឺយើងមិនមែនព្យាយាមបន្ទោសទៅលើបុរសទេ ប៉ុន្តែយើងចង់ស្វែងយល់ឲ្យស៊ីជម្រៅពីរបៀបដែលការរំពឹងទុកក្នុងយេនឌ័រ អាចប៉ះពាល់ដល់សុខភាពទាំងបុរសនិងស្ត្រី។ នៅពេលមិនមានបន្ទុកនៃយេនឌ័រមកលើមនុស្សទេ នោះគ្រប់គ្នានឹងមានជីវិតនិងសុខភាពល្អប្រសើរ។

អ្នកអាចបញ្ចប់សកម្មភាពនេះដោយធ្វើការឆ្លុះបញ្ចាំងមួយអំពីរបៀបធ្វើឲ្យបន្ទុករវាងបុរសនិងស្ត្រីកាន់តែមានតុល្យភាពនឹងគ្នា។ ល្បែងកម្សាន្តដូមីណូ នៅទំព័របន្ទាប់ គឺជាមធ្យោបាយមួយដ៏ល្អដើម្បីបន្តស្វែងយល់អំពីទំនាក់ទំនងរវាងតួនាទីយេនឌ័រ ឋានៈស្ត្រី និងសុខភាពស្ត្រី។

## ល្បែងកម្សាន្តដូមីណូ ដើម្បីស្វែងយល់ពីវិសមភាពយេនឌ័រ និងសុខភាពរបស់ស្ត្រី

សកម្មភាព "តុល្យភាពនៃបន្ទុក" ជួយក្រុមឲ្យពិនិត្យមើលនូវមូលហេតុដែលធ្វើឲ្យស្ត្រីមិនទទួលបានអំណាចនិងការថែទាំសុខភាព យ៉ាងស្មើភាពដូចបុរស ដូចជាទទួលបានការរៀនសូត្រតិច និងធ្វើការងារផ្ទះច្រើនជាដើម។ នៅក្នុងសកម្មភាពបន្ទាប់ អ្នកអាចមើលឃើញពីផលប៉ះពាល់នៃបន្ទុកទាំងនេះ មកលើសុខភាពរបស់ស្ត្រី។ សកម្មភាពនេះដំណើរការដូចគ្នានឹងការលេងល្បែងដូមីណូដែរ ខុសគ្នាត្រង់ថានៅលើដូមីណូនេះ មិនមានចំនួនគ្រាប់តូចៗសម្រាប់រាប់ទេ ប៉ុន្តែវាមានផ្នែក "មូលហេតុ" ឬផ្នែក "ផលប៉ះពាល់" ដែលពាក់ព័ន្ធនឹងសុខភាពស្ត្រីជំនួសវិញ។ "មូលហេតុ" ទាំងនោះបណ្តាលមកពីឋានៈទាបរបស់ស្ត្រី ឬការរំពឹងទុកក្នុងយេនឌ័រ។ "ផលប៉ះពាល់" គឺជាស្ថានភាពដែលនាំឲ្យមានបញ្ហាសុខភាព។ ការងាររបស់ប្រធានក្រុមគឺត្រូវធ្វើឲ្យសកម្មភាពនេះមានភាពរស់រវើកនិងរីករាយដូចការលេងល្បែងដូមីណូដែរ ខណៈដែលព្យាយាមឲ្យពួកគេពិភាក្សាយ៉ាងម៉ត់ចត់អំពីរបៀបដែលឋានៈទាបរបស់ស្ត្រី អាចបង្កបញ្ហាធ្ងន់ធ្ងរដល់សុខភាព ឬថែមទាំងស្លាប់ទៀតផង។ គោលបំណងគឺធ្វើឲ្យមានការពិភាក្សា មិនមែនការធ្វើតេស្តទេ។



*ខ្ញុំបានដឹកនាំក្រុមស្ត្រីមួយក្រុម។ នៅពេលប្រជុំមួយនោះ យើងជជែកអំពីរបៀបដែលស្ត្រីទទួលរងនូវឋានៈទាបនៅក្នុងសហគមន៍។ បន្ទាប់មកខ្ញុំយកគំនិតទាំងឡាយរបស់ស្ត្រីធ្វើជាផ្នែកមូលហេតុនៅក្នុងល្បែងដូមីណូរបស់ខ្ញុំ។ ក្រោយមកទៀត ស្ត្រីបាននាំប្តីរបស់ពួកគេមកចូលរួមការប្រជុំ រួចយើងក៏លេងល្បែងនេះទាំងអស់គ្នា!*

**សកម្មភាព** — **ល្បែងកម្សាន្តដូមីណូ**

## ដើម្បីធ្វើដូមីណូ ៖

កាត់ក្រដាសរាងជាចតុកោណដោយប្រើក្រដាសពណ៌ឬក្រដាសឡាំងចំនួន ១៥ ទៅ២០សន្លឹក (ទំហំ ២១x៣៥ស.ម)។ សន្លឹកក្រដាសនេះជាដូមីណូរបស់អ្នក។

នៅចុងម្ខាងនៃដូមីណូនីមួយៗ មាន "មូលហេតុ" មួយ។ ប្រសិនបើអ្នកបានអនុវត្តសកម្មភាព "តុល្យភាពនៃបន្ទុក" នៅទំព័រ 54-55 រួចហើយ នោះអ្នកប្រហែលជាបានធ្វើសន្លឹកក្រដាសអំពី "មូលហេតុ" រួចហើយ។ ចូរយកវាមកបិតពីលើចុងម្ខាងនៃសន្លឹកដូមីណូទាំងនេះ។ បើមិនមានសន្លឹកមូលហេតុគ្រប់គ្រាន់ទេ អ្នកអាចចម្លងវាថែមទៀតដើម្បីបិតឲ្យគ្រប់ទៅលើដូមីណូទាំងអស់។

ចុងម្ខាងទៀតនៃដូមីណូនីមួយៗគួរសរសេរនូវ "បញ្ហាសុខភាព" ឬផលប៉ះពាល់ទៅលើស្ត្រី ដែលអ្នកអាចសរសេរទុកជាមុន ឬធ្វើក្នុងជំហានទី១នៃសកម្មភាព។ ប្រើហ្វឺតឬក្រដាសពណ៌ផ្សេង ពេលសរសេរពីបញ្ហាសុខភាពនៅចុងម្ខាងទៀតនៃដូមីណូ។

អ្នកអាចចម្លងមូលហេតុ និងផលប៉ះពាល់ឡើងវិញបាន។ ចូរចាំថា អ្នកមិនចាំបាច់ឲ្យផលប៉ះពាល់ ត្រូវគ្នាជាមួយនឹងមូលហេតុនៅគ្រប់ដូមីណូនីមួយៗទេ។ ចូរច្របល់មូលហេតុនិងផលប៉ះពាល់ទាំងនោះចូលគ្នា!



**1** ធ្វើការណែនាំអំពីសកម្មភាព ៖ ប្រាប់ក្រុមឲ្យគិតយ៉ាងឆាប់រហ័សអំពីបញ្ហាសុខភាពដែលស្ត្រីប្រឈម។ ក្នុងពេលដែលពួកគេរៀបរាប់ពីបញ្ហាសុខភាពផ្សេងៗដែលប៉ះពាល់ដល់ស្ត្រី ចូរសរសេរវាលើក្រដាសដែលអាចយកទៅបិតពីលើដូមីណូបាន។ បិតបញ្ហាសុខភាពទាំងនោះនៅលើដូមីណូ ដើម្បីត្រៀមលក្ខណៈលេងល្បែងកម្សាន្ត។

## សកម្មភាព ល្បែងកម្សាន្តដូមីណូ (ត)

❷ បែងចែកពួកគេជាក្រុមៗដែលមានគ្នា ៤ឬ៥នាក់។ ចែកសន្លឹកដូមីណូដល់ក្រុមនីមួយៗ ចំនួនស្មើៗគ្នា។ ដកមួយសន្លឹកចេញដើម្បីចាប់ផ្ដើម រួចដាក់វាទៅលើកម្រាល ឬបិតនៅលើជញ្ជាំង។




❸ ក្រុមនីមួយៗប្តូរវេនគ្នាដើរ។ បន្ទាប់ពីក្រុមទី១ដើររួច ក្រុមបន្ទាប់ត្រូវមើលលើដូមីណូរបស់ខ្លួនថាតើមាន "មូលហេតុ" ឬ "បញ្ហាសុខភាព" ដែលពាក់ព័ន្ធនឹងដូមីណូដែលកំពុងដាក់នៅលើដីនោះឬទេ។ ចូរចាំថា បញ្ហាសុខភាពមួយ អាចមានមូលហេតុច្រើន ហើយបញ្ហាសុខភាពខ្លះអាចពាក់ព័ន្ធនឹងបញ្ហាសុខភាពដទៃទៀត។




ក្រុមទី១ដាក់សន្លឹកដូមីណូដែលបានជ្រើសរើស។ ពួកគេត្រូវពន្យល់ពីទំនាក់ទំនងដែលខ្លួនយល់ឃើញ។ បើគ្រប់គ្នាយល់ស្រប គាត់អាចដាក់ដូមីណូនៅទីនោះបាន។ បើមានខ្លះមិនយល់ស្រប ចូរឲ្យពួកគេជជែកគ្នា, ហើយបើនៅតែខ្វែងគំនិតគ្នាទៀត ក្រុមនោះត្រូវបាត់បង់វេនរបស់ខ្លួន។

ប្រសិនបើក្រុមមួយមិនមានដូមីណូដែលពាក់ព័ន្ធជាមួយមូលហេតុនិងផលប៉ះពាល់ណាមួយទេ នោះពួកគេបាត់បង់វេនរបស់ខ្លួនដែរ។

ក្រុមដែលបានប្រើសន្លឹកដូមីណូអស់មុនគេ គឺជាអ្នកឈ្នះ។

❹ ដើម្បីបញ្ចប់សកម្មភាពនេះ ចូរប្រាប់ក្រុមឲ្យពិភាក្សាថាតើតួនាទីយេនឌ័រនិងកង្វះអំណាចរបស់ស្ត្រី ជាប់ពាក់ព័ន្ធដូចម្តេចខ្លះជាមួយនឹងបញ្ហាសុខភាពដែលស្ត្រីប្រឈម។



អ្នកអាចប្រើវិធី "មែកធាងនៃបញ្ហា" ដើម្បីស្វែងយល់ពីរបៀបដែលតួនាទីយេនឌ័រធ្វើឲ្យស្ត្រីមានបញ្ហាសុខភាពជាច្រើន។ ខ្ញុំបានកែច្នៃចេញពីជំពូកទី៧ ៖ ការពារសុខភាពរបស់ស្ត្រី ដោយប្រើផែនការគ្រួសារ។

# ការប្រាស្រ័យទាក់ទងជាទម្រង់មួយនៃអំណាច




បុគ្គលិកលក្ខណៈមួយដែលគេច្រើនតែគិតថាជារបស់ស្ត្រី គឺភាពអសកម្ម និងការស្តាប់ឱវាទ។ គេមិនរំពឹងថាស្ត្រីនិងក្មេងស្រីគួរតែជជែកវែកញែក ឬប្រឆាំងនឹងពាក្យសម្តីរបស់បុរសទេ។ ជាញឹកញាប់ យោបល់របស់ពួកគេត្រូវបានផាត់ចោល ហើយអាចនឹងត្រូវបានស្តីបន្ទោស ទុកឲ្យនៅម្នាក់ឯង ឬពិន័យ ចំពោះការនិយាយជាសាធារណៈ ឬគ្រាន់តែបញ្ចេញយោបល់ពីអ្វីដែលពួកគេត្រូវការឬចង់បាន។ ការផ្លាស់ប្តូរផ្នត់គំនិតមួយនេះ ត្រូវការភាពក្លាហានជាខ្លាំង ប៉ុន្តែលទ្ធភាពដែលអាចបញ្ចេញយោបល់ជាសាធារណៈ គឺជាទម្រង់មួយនៃអំណាច។

ចូរសិក្សាពីឧទាហរណ៍នៃការប្រាស្រ័យទាក់ទង ៣ប្រភេទខាងក្រោម រួចពិភាក្សាពីគុណសម្បត្តិ និងគុណវិបត្តិរបស់វា។

*បុរសម្នាក់មិនអនុញ្ញាតឲ្យប្រពន្ធទៅចូលរួមប្រជុំសហគមន៍ទេ។ ស្ត្រីដទៃទៀតបានអញ្ជើញប្រពន្ធគាត់ទៅចូលរួម ប៉ុន្តែប្រពន្ធមិនហ៊ានប្រាប់ប្តីថាគាត់ចង់ទៅចូលរួមនោះទេ។*



**ការប្រាស្រ័យទាក់ទងបែបទន់ខ្សោយឬអសកម្ម** ៖ ស្ត្រីធ្វើតាមអ្វីដែលអ្នកដទៃចង់បាន, គិតអំពីអ្នកដទៃជាមុនដែលធ្វើឲ្យលំបាកដល់ខ្លួនឯង, រក្សាភាពស្ងៀមស្ងាត់នៅពេលមានអ្វីរំខាន, និយាយសុំទោសជាញឹកញាប់, យំជាញឹកញាប់, លាក់អារម្មណ៍របស់ខ្លួន, មិនធ្វើអ្វីមួយដើម្បីការពារសិទ្ធិរបស់ខ្លួន។ គាត់ប្រាប់ស្ត្រីទាំងនោះថាគាត់មិនមានចំណាប់អារម្មណ៍ទេ រួចក៏មិនស្តីរកប្តីពេញមួយយប់។



**ការប្រាស្រ័យទាក់ទងបែបបង្ខំឬជម្លោះ** ៖ ស្ត្រីធ្វើអ្វីតាមតែគាត់ចង់បាន ដោយគិតតិចតួចឬមិនគិតទាល់តែសោះពីអ្នកដទៃ, និយាយគំរាម ឬទាមទារ, មិនចង់ស្តាប់អ្នកដទៃ, ឆាប់ខឹងនៅពេលដែលអ្នកដទៃមិនយល់ស្របជាមួយខ្លួន, ស្រែក, ចំអក ឬមើលងាយអ្នកដទៃ។ គាត់ខឹងនឹងស្ត្រីទាំងនោះ ព្រមទាំងស្តីបន្ទោសឲ្យពួកគេថាមិនគួរទៅពាក់ព័ន្ធនឹងអ្វីដែលមិនមានប្រយោជន៍សម្រាប់ខ្លួននោះឡើយ។ ហើយគាត់ខឹងនឹងប្តីរបស់គាត់ ព្រោះប្តីគាត់ទៅចូលរួមការប្រជុំ រីឯគាត់នៅផ្ទះ។



**ការប្រាស្រ័យទាក់ទងបែបមាំមួនឬជឿជាក់** ៖ ស្ត្រីគោរពខ្លួនឯង និងអ្នកដទៃ, ក្រោកឈរទាមទារសិទ្ធិរបស់ខ្លួន, ស្តាប់និងនិយាយតាមសម្រួល, បង្ហាញគំនិតយោបល់ តម្រូវការ និងអារម្មណ៍របស់ខ្លួនយ៉ាងច្បាស់លាស់, និយាយថា "ទេ" ដោយគ្មានអារម្មណ៍ខុសឆ្គង, ស្វែងរកជំនួយនៅពេលត្រូវការ, បង្ហាញភាពជឿជាក់នៅពេលនិយាយ។ គាត់ពន្យល់ប្រាប់ប្តីពីមូលហេតុដែលគាត់ចាប់អារម្មណ៍នឹងការប្រជុំនោះ ហើយគាត់ប្រាប់ប្តីថា "ការប្រជុំធ្វើឡើងតែម្តងតែប៉ុណ្ណោះក្នុង ២សប្តាហ៍ ហើយខ្ញុំពិតជាចង់ចូលរួមខ្លាំងណាស់។ ខ្ញុំនៅតែអាចធ្វើការងារផ្ទះរួចរាល់ដដែល។ តើយើងអាចជជែកគ្នាបានទេ ថាយើងគួរធ្វើបែបណាដើម្បីអាចឲ្យខ្ញុំទៅចូលរួមការប្រជុំបាន?"


www.hesperian.org health guides

អ្នកអាចអនុវត្តការប្រើប្រាស់ការប្រាស្រ័យទាក់ទងបែបជឿជាក់ នៅក្នុងការសម្តែងតួស្តីអំពីការចចារផ្លូវភេទ។ សូមមើលអំពីការប្រាស្រ័យទាក់ទងដើម្បីសម្ពន្ធភាពកាន់តែប្រសើរ (ទំព័រ 97)។

## ការប្រាស្រ័យទាក់ទងកាន់តែច្បាស់ដោយប្រើពាក្យ “ខ្ញុំ”

តើយើងអាចបញ្ចេញអារម្មណ៍ គំនិត និងសេចក្តីត្រូវការរបស់យើងឲ្យកាន់តែច្បាស់តាមរបៀបណា ហើយក្នុងពេលជាមួយគ្នាយើងនៅតែបង្ហាញពីការគោរពចំពោះអ្នកដទៃ? ចូរសាកល្បងនិយាយដោយប្រើពាក្យ "ខ្ញុំ។

ការនិយាយដោយប្រើពាក្យ "ខ្ញុំ" គឺជាវិធីមួយដើម្បីបង្ហាញឲ្យច្បាស់នូវគំនិតរបស់អ្នក ដោយមិនបន្ទោស វាយតម្លៃ ឬគំរាមអ្នកដទៃឡើយ។ អ្នកអាចនិយាយអំពីស្ថានភាពដែលកំពុងប៉ះពាល់មកលើអ្នក តើអ្នកមានអារម្មណ៍បែបណា និងថាតើអ្នកចង់ឃើញអ្វីកើតឡើង។

ការរៀននិយាយដោយប្រើពាក្យ "ខ្ញុំ" អាចមានអារម្មណ៍ប្លែកពេលដំបូង។ វាជាវិធីដ៏រឹងមាំមួយក្នុងការនិយាយ។ ប៉ុន្តែនៅពេលសាកល្បងប្រើក្នុងសម្ពន្ធភាពរបស់ពួកគេ ហើយក្លាយជាទម្លាប់ នោះពួកគេនឹងឃើញថាវាមានប្រសិទ្ធភាពល្អ។

### សកម្មភាព — របៀបនិយាយដោយប្រើពាក្យ “ខ្ញុំ”

1. ដំបូងចូរនិយាយពីអ្វីដែលរំខានដល់អ្នក និងថាតើវាធ្វើឲ្យអ្នកមានអារម្មណ៍បែបណា។ អ្នកអាចនិយាយច្រើនថែមទៀតពីអ្វីដែលរំខានដល់អ្នក ប៉ុន្តែត្រូវនិយាយដោយកុំបន្ទោសឬជេរស្តីនរណាម្នាក់ឡើយ។
2. បន្ទាប់មកនិយាយពីអ្វីដែលអ្នកចង់បាន។ ជាការសំខាន់គឺមិនត្រូវធ្វើការទាមទារ ឬចាត់ទុកវាជាតម្រូវការដាច់ខាតនោះឡើយ។ បើមិនដូច្នេះទេ សំណើរបស់អ្នកនឹងមានលក្ខណៈបង្ខំ។
3. បន្ទាប់មកសួរអ្នកដទៃទៀតថាតើពួកគេមានអារម្មណ៍បែបណាចំពោះពាក្យសម្តីឬសំណើរបស់អ្នក។



## ជួយគាំទ្រគ្រូបណ្តុះបណ្តាល

ការជួយគាំទ្រស្ត្រីឲ្យក្លាយជាអ្នកប្រាស្រ័យទាក់ទងដ៏ល្អ មានន័យថាអ្នកជាអ្នកប្រាស្រ័យទាក់ទងដ៏ល្អខ្លួនឯងដែរ។ មនុស្សគ្រប់គ្នាដែលធ្វើការងារនេះសុទ្ធតែត្រូវការការជួយគាំទ្រ។ ចូរត្រៀមលក្ខណៈរួចរាល់មុននឹងចាប់ផ្តើមអនុវត្តសកម្មភាពមួយ។ អ្នកគួរសាកល្បងឬនិយាយជាមួយនរណាម្នាក់ជាមុន ដើម្បីឲ្យមានចិត្តស្ងប់នៅពេលដឹកនាំអនុវត្តសកម្មភាពណាមួយ។ ត្រូវប្រាកដថាអ្នកដែលស្តាប់នោះ អាចធ្វើការឆ្លុះបញ្ចាំងឡើងវិញក្រោយសកម្មភាពបានបញ្ចប់។




# ក្រុមបុរសដែលធ្វើការងារដើម្បីសមភាពយេនឌ័រ

ស្ត្រីតែងតែ និងនៅតែជាកម្លាំងរុញច្រានដ៏សំខាន់មួយឆ្ពោះទៅកាន់សមភាពយេនឌ័រ។ វាជាការលំបាកសម្រាប់បុរសមួយចំនួនក្នុងការទទួលយកនូវគំនិតមួយដែលជំរុញឲ្យចែករំលែកអំណាចនិងសិទ្ធិពិសេសយ៉ាងស្មើគ្នាជាមួយស្ត្រី។ មានបុរសជាច្រើនមិនព្រមទទួលយកការផ្លាស់ប្តូរណាមួយក្នុងតួនាទីយេនឌ័រដែលអនុញ្ញាតឲ្យស្ត្រីអាចគ្រប់គ្រងជីវិតផ្ទាល់ខ្លួនរបស់ពួកគេនោះទេ។ ទោះជាយ៉ាងនេះក្តី ក៏មានបុរសកាន់តែច្រើនឡើងៗដែលទទួលយកនិងគាំទ្រដល់ការផ្លាស់ប្តូរនានាដែលលើកកម្ពស់ឋានៈរបស់ស្ត្រី ពីព្រោះពួកគេយល់ដឹងថា សមភាពយេនឌ័រអាចកែលម្អគុណភាពជីវិតរបស់មនុស្សគ្រប់គ្នា។

ជាញឹកញាប់ បុរសត្រូវបានជំរុញទឹកចិត្តក្នុងការងារដើម្បីសមភាពយេនឌ័រ ព្រោះពួកគេយល់ថាវាផ្នែកមួយដ៏សំខាន់នៃការតស៊ូផ្សេងទៀតដើម្បីយុត្តិធម៌ ដូចជាការគ្រប់គ្រងដីធ្លីនិងធនធាន ការទទួលបានការអប់រំនិងការថែទាំសុខភាព និងសេរីភាពពីហិង្សា។

សកម្មភាពផ្សេងៗទៀតដូចជា "ការងារក្នុងមួយថ្ងៃ" (ទំព័រ 48 ដល់ 49) និង "ប្រអប់យេនឌ័រ" (ទំព័រ 44 ដល់ 45) អាចជួយឲ្យបុរសស្វែងយល់ និងមានក្តីអាណិតអាសូរដល់ភាពលំបាកវេទនាផ្សេងៗដែលស្ត្រីជួបប្រទះដោយសារតែវិសមភាពយេនឌ័រ។ ប្រហែលជាមានបុរសមួយចំនួនកំពុងតែរិះរកវិធីរួចទៅហើយអំពីថាតើការផ្លាស់ប្តូរការរំពឹងទុកក្នុងយេនឌ័រ អាចផ្តល់ផលប្រយោជន៍អ្វីខ្លះដល់បុរសនិងស្ត្រីទាំងអស់គ្នា។

## បុរសវ័យក្មេងសាមគ្គីគ្នាប្រឆាំងនឹងមោទនភាពហួសហេតុនៃភាពជាបុរស

នៅប្រទេសអេក្វាឌ័រ ការបង្ហាញចេញនូវអំណាចផ្លូវភេទ និងឥរិយាបថបង្អិតបង្អំនៅក្នុងផ្ទះនិងទីសាធារណៈ គឺជារបៀបមួយដែលពួកគេបង្ហាញពីភាពជាបុរសរបស់ខ្លួន។ ប៉ុន្តែឥរិយាបថបែបនេះកំពុងទទួលការផ្លាស់ប្តូរហើយ គឺដោយសារបុរសវ័យក្មេងជំនាន់ក្រោយ ដែលក្នុងនោះរួមមានក្រុមមួកពណ៌ផ្កាឈូក (Cascos Rosa)។ ពាក់អាវយឺតពណ៌ផ្កាឈូក បុរសវ័យក្មេងទាំងនេះធ្វើការងារដើម្បីលើកកម្ពស់ឥរិយាបថបែបថ្មីដែលអំពាវនាវឲ្យមានការបញ្ឈប់ហិង្សាលើស្ត្រី វិសមភាពយេនឌ័រ និងការបំពានផ្លូវភេទ។




ក្រុមបុរសមួកពណ៌ផ្កាឈូក ដឹកនាំកម្មវិធីវិទ្យុមួយសម្រាប់យុវជន ដែលធ្វើការពិភាក្សាប្រកបដោយភាពច្នៃប្រឌិតនិងបើកចំហអំពីបញ្ហាផ្លូវភេទ ហិង្សាក្នុងយេនឌ័រ និងប្រធានបទដទៃទៀត។

ក្រុមមួកពណ៌ផ្កាឈូក ត្រូវបានបង្កើតឡើងដំបូងនៅឆ្នាំ២០១០ ដោយបុរសវ័យក្មេងមួយក្រុមតូចដែលបានទទួលវគ្គបណ្តុះបណ្តាលពីគម្រោងសកម្មភាពដើម្បីប្រជាធិបតេយ្យនិងការអភិវឌ្ឍ។ ពួកគេបានរៀនអំពីអំណាចដែលបុរសមានលើស្ត្រីដែលរារាំងមិនឲ្យស្ត្រីទទួលបានភាពរីករាយក្នុងសិទ្ធិនិងសេរីភាពរបស់ខ្លួនដែលមាន អំពីអំពើហិង្សាលើស្ត្រី និងអំពីរបៀបផ្សេងៗក្នុងការបង្ហាញភាពជាបុរស។

ចាប់ពីពេលនោះមក ក្រុមមួកពណ៌ផ្កាឈូកបានរីកដុះដាលជាលំដាប់ ហើយពេលនេះមានរួមបញ្ចូលទាំងស្ត្រីវ័យក្មេងទៀតផង។ ពួកគេធ្វើការពន្យល់ណែនាំ និងរៀបចំសកម្មភាពបង្កើនការយល់ដឹងនានានៅតាមសាលារៀន សហគមន៍ និងទីកន្លែងដែលប្រជាជនវ័យក្មេងជួបជុំគ្នា ដូចជាកម្មវិធីប្រគុំតន្ត្រីជាដើម។ ពួកគេយល់ថាការផ្លាស់ប្តូរមិនមែនកើតឡើងឆាប់ៗនោះទេ។ ពួកគេចង់ឲ្យប្រជាជនចាប់ផ្តើមគិតអំពីការផ្លាស់ប្តូរនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់ពួកគេម្នាក់ៗ ដើម្បីធ្វើឲ្យសង្គមទាំងមូលមានការផ្លាស់ប្តូរដោយផ្អែកទៅលើសមភាព សិទ្ធិមនុស្ស និងភាពយុត្តិធម៌។

ដាមៀន វ៉ាលិនសៀ (Damián Valencia) ដែលជាសមាជិកស្ថាបនិកម្នាក់ បានរៀបរាប់ពីអ្វីដែលបានកើតឡើងនៅក្នុងផ្ទះរបស់គាត់ចាប់ពីពេលដែលគាត់បានចូលរួមក្នុងក្រុមមក។ គាត់និយាយថា "អ្វីគ្រប់យ៉ាងបានផ្លាស់ប្តូរជាពិសេសឪពុករបស់ខ្ញុំ។ គាត់មិនដែលធ្វើការងារផ្ទះអ្វីឡើយ តែឥឡូវគាត់លាងចាន ហើយជួនកាលអ៊ុតខោអាវទៀតផង។ ការផ្លាស់ប្តូរនេះធ្វើឲ្យម្តាយខ្ញុំរីករាយជាងមុន ព្រោះបន្ទុករបស់គាត់ត្រូវបានសម្រាល។ បុរសវ័យក្មេងជាច្រើនទៀតនិយាយថា ក្រុមគ្រួសាររបស់ពួកគេក៏មានការផ្លាស់ប្តូរស្រដៀងគ្នានឹងក្រុមគ្រួសាររបស់ដាមៀនដែរ។ ការប្រាស្រ័យទាក់ទងរវាងឪពុកម្តាយរបស់ពួកគេ មានភាពប្រសើរឡើង ហើយហិង្សាក្នុងគ្រួសារក៏មិនសូវមានទៀតផង, ទាំងអស់គ្នាសុទ្ធតែទទួលបានផលប្រយោជន៍។

## ហាស៊ីក៖ សិក្ខាសាលាយេនឌ័រសម្រាប់បុរស

ក្រុមការងារមួយនៅប្រទេសហ្វីលីពីន ដែលមានឈ្មោះកាត់ហៅថា " ហាស៊ីក" (HASIK: Harnessing Self-reliant Initiatives and Knowledge) បានបង្កើតសិក្ខាសាលារយៈពេល៣ថ្ងៃដើម្បីបង្កើនការយល់ដឹងអំពីយេនឌ័រសម្រាប់បុរស។ ក្រុមការងារហាស៊ីក យល់ថាប្រជាជន (ព្រមទាំងអង្គការ និងសហគមន៍) ទំនងជាធ្វើការផ្លាស់ប្តូរ នៅពេលដែលពួកគេបានយល់ដឹងស៊ីជម្រៅអំពីបញ្ហានានាដែលស្ត្រីប្រឈមពីបញ្ហាវិសមភាពយេនឌ័រ, មានអារម្មណ៍ដិតដាមជាមួយនឹងបញ្ហាទាំងនេះ, និងមើលឃើញពីរបៀបធ្វើការផ្លាស់ប្តូរ។




មិនមែនបុរសទាំងអស់សុទ្ធតែមើលឃើញពីគ្រោះថ្នាក់ដែលបង្កឡើងដោយសារវិសមភាពយេនឌ័រនោះទេ ជាពិសេសទំហំនៃភាពឈឺចាប់ដែលស្ត្រីទទួលបានដោយសារបញ្ហានេះ។ ក្រុមការងារហាស៊ីក ដឹងថាជោគជ័យអាចកើតឡើងគឺអាស្រ័យលើការជួយឲ្យបុរសមើលឃើញពីភាពលំបាកទាំងនេះ និងពីតួនាទីរបស់បុរសនៅក្នុងបញ្ហា, ដោយមិនធ្វើឲ្យពួកគេទទួលភាពអាម៉ាសដោយសារកង្វះខាតការយល់ដឹងរបស់ពួកគេនោះទេ។

ដើម្បីជួយឲ្យបុរសមិនមានអារម្មណ៍ទើសទាល់ ជាដំបូងអ្នកសម្របសម្រួលត្រូវអនុញ្ញាតឲ្យពួកគេលេងសើច ជជែក និងចែករំលែកពីយោបល់របស់ពួកគេចំពោះស្ត្រី ដោយមិនមានការកែតម្រូវឬរំខានឡើយ។ ពួកគេក៏ពិភាក្សាអំពីតួនាទីរបស់បុរសនិងស្ត្រី (មើលសកម្មភាព "ប្រអប់យេនឌ័រ" នៅទំព័រ 44) ផងដែរ។ ដោយសារគ្មានការរិះគន់លើបុរសទាំងនេះ នោះពួកគេនិយាយដោយបើកចំហ និងមិនមានអារម្មណ៍តានតឹង។

បន្ទាប់មក ពួកគេទស្សនាបទបង្ហាញមួយដែលត្រូវបានបង្កើតឡើងដើម្បីជួយឲ្យពួកគេមានចិត្តអាណិតអាសូរដល់ភាពលំបាករបស់ស្ត្រី។ បទបង្ហាញដែលមានចំណងជើងថា "ស្តាប់មតិស្ត្រី យល់ពីភាពឈឺចាប់របស់ពួកគេ" រួមបញ្ចូលនូវបទចម្រៀងអំពីជីវិតនិងការប្រាស្រ័យទាក់ទងរបស់ស្ត្រី ដោយប្រើប្រាស់រូបភាព វីដេអូ រឿងរ៉ាវផ្ទាល់ខ្លួន និងការណ៍ពិតផ្សេងៗ ដូចជារបៀបដែលស្ត្រីជាច្រើនត្រូវបានរើសអើងនៅក្នុងការងារ ទទួលរងហិង្សានិងភាពឈឺចាប់ដោយសារតែមានឋានៈទាបនៅក្នុងយេនឌ័រ។ នៅផ្នែកខ្លះនៃបទបង្ហាញបានធ្វើឲ្យបុរសពិចារណាទៅលើសកម្មភាពនិងឥរិយាបទរបស់ខ្លួនចំពោះបញ្ហាដែលបានកើតឡើង។ អ្នកចូលរួមជាច្រើនមានភាពក្តុកក្តួលយ៉ាងខ្លាំងនៅពេលទស្សនាបទបង្ហាញនេះ បន្ទាប់មកពួកគេបានយកចិត្តទុកដាក់កាន់តែខ្លាំងនៅក្នុងការពិភាក្សា។

អ្នកសម្របសម្រួលនៃក្រុមការងារហាស៊ីក សង្កេតឃើញថាមកដល់ចំណុចនេះ មានបុរសជាច្រើនបានយល់ដឹងកាន់តែស៊ីជម្រៅអំពីបញ្ហានានាដែលស្ត្រីប្រឈម ប៉ុន្តែមានខ្លះទៀតនៅតែមិនសូវយល់ ឬមិនយកចិត្តទុកដាក់នឹងបញ្ហាវិសមភាពយេនឌ័រនេះទេ។ ដើម្បីជំរុញការយល់ដឹងបន្ថែមរបស់អ្នកចូលរួម ក្រុមការងារហាស៊ីកបានបង្កើតជាសកម្មភាពក្រុមមួយដែលមានការប្រកួតប្រជែងគ្នា។ ក្រុមនីមួយៗព្យាយាមធ្វើការពន្យល់ឲ្យបានល្អបំផុតអំពីមូលហេតុដែលបណ្តាលឲ្យមានវិសមភាពយេនឌ័រ។ ដើម្បីទទួលបានពិន្ទុ បុរសទាំងនោះត្រូវតែលើកយកហេតុផលសមរម្យបំផុតដើម្បីបញ្ចុះបញ្ចូលអ្នកដទៃ។ ឆ្លងកាត់ដំណើរការនេះ បុរសកាន់តែច្រើនបានយល់ដឹងយ៉ាងស៊ីជម្រៅ។ ដើម្បីស្វែងយល់ពីសកម្មភាពស្រដៀងគ្នានេះ សូមមើលសកម្មភាព "ការប្រកាន់ជំហរមួយ" (ទំព័រ 261)។

ជាមួយនឹងការយល់ដឹង សេចក្តីមេត្តា និងការបារម្ភអំពីស្ត្រីដែលនៅជិតខ្លួនរបស់ពួកគេ បុរសក៏ចាប់ផ្តើមពិចារណាអំពីការផ្លាស់ប្តូរ។ ដោយប្រើប្រាស់សកម្មភាព "ល្ខោនកាយវិការ" បុរសក្រឡេកមើលទៅលើភាពអយុត្តិធម៌ ឬក្តីអស់សង្ឃឹមរបស់ស្ត្រី រួចធ្វើការផ្លាស់ប្តូរ។ វាជួយឲ្យបុរសគិតអំពីរបៀបផ្លាស់ប្តូរនៅក្នុងឆាកជីវិត ក្នុងការប្រាស្រ័យទាក់ទង និងក្នុងសហគមន៍របស់ពួកគេផ្ទាល់។ សេចក្តីណែនាំអំពីសកម្មភាព "ល្ខោនកាយវិការ" មានផ្តល់ជូននៅទំព័របន្ទាប់។

សិក្ខាសាលានេះបញ្ចប់ទៅដោយការប្រារព្ធពិធីសាសនាមួយ។ បុរសទាំងនោះចំណាយពេល១៥នាទីយ៉ាងស្ងៀមស្ងាត់ពិចារណាថាតើការបណ្តុះបណ្តាលអំពីយេនឌ័រនេះមានឥទ្ធិពលអ្វីខ្លះទៅលើជីវិតរបស់ពួកគេផ្ទាល់។ បន្ទាប់មកបុរសម្នាក់ៗរៀបរាប់ពីវិធីមួយដែលគាត់ប្តេជ្ញាផ្តល់តម្លៃដល់ភាពយុត្តិធម៌ចំពោះស្ត្រី នៅក្នុងគ្រួសារឬសហគមន៍របស់គាត់។ បន្ទាប់ពីការស្តាប់ ជជែកវែកញែក និងសកម្មភាពប្លែកៗរយៈពេល៣ថ្ងៃរួចមក ចូរប្រាប់ពួកគេឲ្យពិចារណាពីគំនិតថ្មី។ ជាញឹកញាប់ ការឆ្លុះបញ្ចាំងនេះនឹងនាំឲ្យមានការផ្លាស់ប្តូរផ្ទាល់ខ្លួន ដែលប្រែក្លាយបុរសឲ្យទៅជាសកម្មជនយេនឌ័រម្នាក់ដែលធ្វើការតស៊ូដើម្បីកែលម្អជីវភាព សុខភាព និងសិទ្ធិរបស់ស្ត្រីនៅក្នុងសហគមន៍របស់ពួកគេ។

## សកម្មភាព ល្ខោនកាយវិការ

នៅក្នុងសកម្មភាពនេះ មានមនុស្ស ៣ក្រុម៖ រូបចម្លាក់ ជាងចម្លាក់ និងទស្សនិកជន។ អ្នកដើរតួជារូបចម្លាក់ នឹងសម្តែងកាយវិការនឹងថ្កល់មួយ ដោយបង្ហាញអំពីតួនាទី ឬសកម្មភាពមួយ។ រូបចម្លាក់បង្ហាញអារម្មណ៍របស់ខ្លួនចេញមកក្រៅតាមរយៈកាយវិការ។ ជាងចម្លាក់អាចធ្វើចលនាឲ្យរូបចម្លាក់ ប៉ុន្តែមិនអាចនិយាយជាមួយបានទេ។ ទស្សនិកជនធ្វើការវិភាគ ថាតើកំពុងមានអ្វីកើតឡើង ហើយផ្តល់ការណែនាំថាតើជាងចម្លាក់អាចផ្លាស់ប្តូរទស្សនីយភាពបែបណា។ ចូរប្រើសម្ភារនិងសម្លៀកបំពាក់ជាជំនួយ។




1. ជ្រើសរើសអ្នកសម្តែងមួយចំនួនឲ្យធ្វើជាជាងចម្លាក់ ឬរូបចម្លាក់។ ជួយពួកគេឲ្យជ្រើសរើសទស្សនីយភាពមួយដើម្បីធ្វើការបង្ហាញ ដោយក្នុងនោះពួកគេសម្តែងអំពីបញ្ហាយេនឌ័រដែលជួបប្រទះញឹកញាប់ ហើយដែលក្រុមបានពិភាក្សារួចហើយ ដូចជាប្រពន្ធចម្អិនអាហារនិងមើលកូន ហើយប្តីរបស់គាត់ផឹកស្រា, បុរសចំណាស់ម្នាក់កំពុងបំពានលើស្ត្រីវ័យក្មេង២នាក់នៅតាមដងផ្លូវ, បុរសម្នាក់កំពុងស្រែកសម្លុតមិត្តស្រីរបស់គាត់ដោយលើកដៃប្រុងនឹងទះ។

2. សួរទស្សនិកជនថាតើពួកគេមើលឃើញអ្វីខ្លះ បន្ទាប់មកអនុញ្ញាតឲ្យជាងចម្លាក់កែប្រែកាយវិការរបស់រូបចម្លាក់ដើម្បីឲ្យមានលទ្ធផលវិជ្ជមាន។ លើកទឹកចិត្តទស្សនិកជនឲ្យផ្តល់យោបល់ត្រឡប់ឲ្យបានច្រើន ដោយសួរពួកគេថាតើអ្វីខ្លះបានផ្លាស់ប្តូរ ឬអាចធ្វើឲ្យកាន់តែប្រសើរបែបណាទៀត និងថាតើកាយវិការនេះមើលទៅដូចអ្វី។ បន្ទាប់មក ទស្សនិកជនអាចដើរចូលការសម្តែងដើម្បីកែលម្អទស្សនីយភាពបន្ថែមទៀត។

3. នៅពេលចប់ជុំទាំង២នេះហើយ ចូរពិភាក្សាអំពីល្ខោនកាយវិការ។ តើទស្សនីយភាពត្រូវបានផ្លាស់ប្តូរដូចម្តេចខ្លះ? តើមានការសម្តែងណាដែលធ្វើឲ្យពួកគេនឹកឃើញពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេដែរឬទេ? បើមាន តើសកម្មភាពនោះបានផ្លាស់ប្តូរការគិតរបស់ពួកគេចំពោះបទពិសោធន៍នោះដែរឬទេ? តើបុរសអាចផ្លាស់ប្តូរសកម្មភាពរបស់គាត់យ៉ាងដូចម្តេចប្រសិនបើគាត់ជួបស្ថានភាពស្រដៀងនឹងទស្សនីយភាពនោះ?

# ការចិញ្ចឹមកូនប្រុសនិងកូនស្រីដោយស្មើភាពគ្នា

កុមារចាប់ផ្តើមរៀនសូត្រពីការរំពឹងទុកក្នុងយេនឌ័រ តាំងពីតូចមកម្ល៉េះ។ តួនាទីយេនឌ័រទាំងនេះច្រើនតែនាំឲ្យមានភាពមិនស្មើគ្នាក្នុង ការទទួលបានធនធាននិងអំណាចក្នុងការសម្រេចចិត្ត ដែលធ្វើឲ្យមានគ្រោះថ្នាក់ដល់សុខភាពរបស់ស្ត្រី។ វិធីមួយដើម្បីធានាថាក្មេងប្រុសនិងក្មេងស្រីនឹងទទួលបានតម្លៃស្មើគ្នា គឺការចិញ្ចឹមពួកគេប្រកបដោយការរំពឹងទុក សិទ្ធិ និងការទទួលខុសត្រូវដូចៗគ្នា។

## ផ្លាស់ប្តូររបៀបបង្រៀនយេនឌ័រដល់ក្មេងប្រុសស្រី

មានវិធីជាច្រើនដែលឪពុកម្តាយ គ្រូបង្រៀន និងមនុស្សពេញវ័យដទៃទៀតអាចជួយដល់កុមារគ្រប់ៗគ្នាដើម្បីឲ្យពួកគេអភិវឌ្ឍសមត្ថភាពយ៉ាងពេញលេញ យ៉ាងស្មើភាពគ្នា និងមិនស្ថិតក្រោមការរំពឹងទុកនៃយេនឌ័រដ៏គ្រោះថ្នាក់នោះទេ។ ឪពុកម្តាយអាចផ្តល់ការគាំទ្រចំពោះគ្នាទៅវិញទៅមក តាមរយៈការជួបជុំយ៉ាងទៀតទាត់ដើម្បីជជែកអំពីបញ្ហាយេនឌ័រដែលប៉ះពាល់ដល់ការចិញ្ចឹមបីបាច់កូនៗរបស់ពួកគេ។

មនុស្សពេញវ័យអាចបង្រៀនក្មេងស្រីនិងក្មេងប្រុស ឲ្យផ្តល់ការគោរពចំពោះគ្នាទៅវិញទៅមក ចែករំលែករបស់របរស្មើៗគ្នា និងរួមគ្នាធ្វើកិច្ចការផ្ទះទាំងអស់គ្នា។ ក្មេងប្រុសមិនគួរទទួលបានការចម្អកនៅពេលបង្ហាញមនោសញ្ចេតនានោះទេ ជាពិសេសអារម្មណ៍ភ័យខ្លាច ឬទុក្ខព្រួយ។ មនុស្សពេញវ័យអាចជួយក្មេងប្រុសឲ្យបង្ហាញអារម្មណ៍របស់ពួកគេចេញមកក្រៅ ហើយក៏អាចជួយក្មេងស្រីឲ្យនិយាយចេញនូវគំនិតនិងអារម្មណ៍របស់ពួកគេ ដោយមិនបារម្ភពីការបដិសេធ ឬសើចចម្អកឲ្យនោះដែរ។

ទាំងក្មេងប្រុសនិងក្មេងស្រីអាចរៀនធ្វើការងារផ្ទះគ្រប់ប្រភេទ ព្រមទាំងចែករំលែកការទទួលខុសត្រូវដូចគ្នា ដូចជាចម្អិនអាហារ សម្អាតផ្ទះ មើលប្អូនតូច ដាំដំណាំនិងមើលសត្វ និងប្រើប្រាស់ឧបករណ៍និងម៉ាស៊ីនផ្សេងៗ។



ក្រុមឪពុកម្តាយអាចធ្វើការរៀបចំមួយដើម្បីធានាថាក្មេងស្រីនិងក្មេងប្រុសមានឱកាសដូចគ្នានៅសាលារៀន ដូចជាការលេងកីឡា និងការរៀនមុខវិជ្ជាផ្សេងៗ។ មនុស្សពេញវ័យអាចជួយកុមារឲ្យបង្កើតកម្មវិធីកម្សាន្តដោយប្រើកូនតុក្កតាដើម្បីសម្តែងរឿងផ្សេងៗដែលមិនដាក់កំហិតតួនាទីយេនឌ័រឡើយ។ (ឧទាហរណ៍មួយដូចជា រឿងនិទានអំពីក្មេងស្រីម្នាក់ជួយសង្គ្រោះក្មេងប្រុសម្នាក់ពីសត្វចម្លែក គឺមិនមែនក្មេងប្រុសតែងតែសង្គ្រោះក្មេងស្រីជានិច្ចនោះទេ)។

ម្យ៉ាងទៀតគួរជជែកណែនាំកុមារអំពីរឿងនិទាន និងអត្ថបទទស្សនាវដ្តីដែលពួកគេបានអាន ចម្រៀងដែលបានស្តាប់ និងកម្មវិធីទូរទស្សន៍និងវីដេអូដែលបានមើល រួចជួយឲ្យពួកគេពិចារណាឡើងវិញអំពីតួនាទីយេនឌ័រទាំងឡាយដែលបានបង្កប់នៅក្នុងប្រព័ន្ធផ្សព្វផ្សាយទាំងនេះដែលនាំឲ្យមានផលមិនល្អ។

## សកម្មភាព ការកែប្រែក្បួនច្បាប់




1 ប្រាប់ពួកគេឲ្យរៀបរាប់ពីព្រឹត្តិការណ៍សំខាន់ៗដែលក្មេងប្រុសនិងក្មេងស្រីបានជួបប្រទះក្នុងឆាកជីវិតរបស់ពួកគេ។ សរសេរចូលនូវរាល់គំនិតទាំងឡាយដែលមាន។

2 សួរថាតើការរំពឹងទុកក្នុងយេនឌ័រ អាចប៉ះពាល់ដល់ព្រឹត្តិការណ៍ប្រពៃណីយ៉ាងដូចម្តេច, ឧទាហរណ៍៖

- តើការសម្រាលបានកូនប្រុស មានភាពខុសគ្នាពីការសម្រាលបានកូនស្រីដូចម្តេចខ្លះ?
- រវាងបុរសវ័យក្មេងនិងស្ត្រីវ័យក្មេង តើការរំពឹងទុកអំពីអាពាហ៍ពិពាហ៍របស់ពួកគេ មានភាពខុសគ្នាដូចម្តេចខ្លះ?
- តើភាពខុសគ្នាទាំងនេះ មានភាពចាំបាច់ឬសារៈសំខាន់ដែរឬទេ? ហេតុអ្វី? តើមានផលប្រយោជន៍អ្វីខ្លះពីការមានព្រឹត្តិការណ៍ប្រពៃណីខុសគ្នាសម្រាប់ក្មេងស្រីនិងក្មេងប្រុស? តើការមានព្រឹត្តិការណ៍ប្រពៃណីស្រដៀងគ្នាសម្រាប់ក្មេងប្រុសនិងក្មេងស្រី អាចផ្តល់ផលប្រយោជន៍អ្វីខ្លះវិញ?
- នៅពេលអ្នកកំពុងចម្រើនវ័យ (ឬកំពុងចិញ្ចឹមកូន) តើព្រឹត្តិការណ៍ប្រពៃណីខុសគ្នាទាំងនេះធ្វើឲ្យអ្នកមានអារម្មណ៍បែបណា?

3 បែងចែកអ្នកចូលរួមជាក្រុមតូចៗ រួចប្រាប់ឲ្យក្រុមនីមួយៗជ្រើសរើសយកព្រឹត្តិការណ៍មួយ។ ក្នុងព្រឹត្តិការណ៍នីមួយៗ ប្រាប់ក្រុមឲ្យពិចារណាដើម្បីពន្យល់ថាក្មេងស្រីនិងក្មេងប្រុសត្រូវបានឲ្យតម្លៃស្មើៗគ្នា។

4 ឲ្យពួកគេចូលរួមក្នុងក្រុមធំតែមួយវិញ ហើយឲ្យពួកគេរៀបរាប់ពីគំនិតរបស់ខ្លួន។

5 ដើម្បីបញ្ចប់សកម្មភាពនេះ ចូរធ្វើផែនការពីរបៀបនាំយកគំនិតទាំងនេះទៅបណ្តុះក្នុងសហគមន៍របស់ពួកគេ។



**ការប្រៀនប្រដៅ** អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការបណ្ដុះការផ្ដល់តម្លៃដល់ខ្លួនឯង របស់មនុស្សម្នាក់។ ការយកចិត្តទុកដាក់ចំពោះមនុស្សចាស់ បានជួយឲ្យក្មេងស្រីជាច្រើនផ្លាស់ប្ដូរការរំពឹងទុករបស់ខ្លួនអំពីថាតើគេជានរណា ហើយអាចមានអ្វីកើតឡើងចំពោះគេ។ ស្រដៀងគ្នានេះដែរ ក្មេងប្រុសអាចទទួលបានប្រយោជន៍ពីការប្រៀនប្រដៅឲ្យយល់ពីអារម្មណ៍និងការទទួលខុសត្រូវរបស់ក្មេងស្រី។ មនុស្សចាស់អាចជាគ្រូម្នាក់ដែលមើលឃើញពីចំណុចខ្លាំងរបស់ក្មេងស្រីម្នាក់ រួចជំរុញឲ្យក្មេងនោះអភិវឌ្ឍនចំណុចខ្លាំងរបស់ខ្លួនឲ្យកាន់តែរឹងមាំ។ អ្នកប្រៀនប្រដៅដទៃទៀតមានដូចជាម្ដាយមីង ដែលមើលថែក្មេងៗ ជួយឲ្យពួកគេយល់ដឹងពីសមត្ថភាពរបស់ខ្លួន ព្រមទាំងប្រឹងប្រែងសម្រេចគោលដៅរបស់ខ្លួន។

## ក្រុមក្មេងស្រីក្លាយជាអ្នកដឹកនាំ

អង្គការបណ្ដាញក្មេងស្រីតូច ត្រូវបានចាប់ផ្ដើមឡើងដោយអ្នកគ្រូម្នាក់នៅប្រទេសហ្ស៊ីមបាវេ។ គាត់គឺជាជនរងគ្រោះម្នាក់ពីការរំលោភផ្លូវភេទកាលពីនៅកុមារ។ គាត់ រួមជាមួយសមាជិកស្ថាបនិកដទៃទៀតដែលខ្លះជាជនរងគ្រោះពីការរំលោភកាលពីនៅកុមារផងដែរ និងសព្វថ្ងៃជាសមាជិករបស់អង្គការមួយនេះ, បានបង្កើតវិធីសាស្ត្រព្យាបាលភាពឈឺចាប់ផ្លូវចិត្តនិងគាំទ្រដល់ស្ត្រី ដោយផ្ដោតលើការផ្ដល់តម្លៃដល់ខ្លួនឯងនិងភាពជាអ្នកដឹកនាំ។ វិធីសាស្ត្រនេះធ្វើឲ្យស្ត្រីវ័យក្មេងមានសមត្ថភាព និងយល់ដឹងពីសិទ្ធិរបស់ខ្លួន ព្រមទាំងអាចធ្វើការតស៊ូមតិដើម្បីសិទ្ធិរបស់ក្មេងស្រីទៀតផង។ ពួកគេមានគោលដៅច្បាស់លាស់សម្រាប់ខ្លួនឯង និងធ្វើផែនការដើម្បីសម្រេចគោលដៅទាំងនោះ។ ពួកគេក៏ចេះពីរបៀបការពារខ្លួននៅពេលមាននរណាម្នាក់បំពានលើពួកគេ ហើយពួកគេអាចផ្ដល់ការគាំទ្រដល់ក្មេងស្រីដទៃទៀតដែលអស់សង្ឃឹមក្នុងជីវិតផងដែរ។

សកម្មភាពដ៏សំខាន់មួយនៃអង្គការបណ្ដាញក្មេងស្រីតូច គឺឆ្លើយតបចំពោះគ្រប់ករណីនៃការបំពាន ដោយផ្ដល់មធ្យោបាយដល់ក្មេងស្រីឲ្យរួចផុតពីស្ថានភាពគ្រោះថ្នាក់, សហការជាមួយប៉ូលីសនិងអង្គការសេវាសង្គមផ្សេង, និងបង្កើនការយល់ដឹងតាមគ្រួសារនិងសហគមន៍ អំពីសិទ្ធិរបស់ក្មេងស្រី។



គន្លឹះនៃការជួយក្មេងស្រីឲ្យក្លាយជាអ្នកដឹកនាំជាជាងជនរងគ្រោះនោះគឺតាមរយៈក្លឹបផ្ដល់អំណាចដល់ក្មេងស្រី ដែលជាទូទៅស្ថិតនៅតាមសាលារៀន។ ដោយមានការជួយគាំទ្រពីគ្រូបង្ហាត់ ក្មេងស្រីធ្វើការជាមួយគ្នាក្នុងសកម្មភាពនានាដើម្បីបង្កើនជំនាញនិងភាពជឿជាក់របស់ពួកគេ។ ពួកគេពិភាក្សាពីក្ដីសង្ឃឹមនិងសុបិនរបស់ខ្លួន ក៏ដូចជាបទពិសោធន៍ផ្ទាល់ខ្លួនអំពីការបំពាននិងការរឹតត្បិតអំណាច។ ពួកគេសិក្សានិងវែកញែកអំពីទិដ្ឋភាពផ្សេងៗនៃវិសមភាពយេនឌ័រ និងសិទ្ធិមនុស្ស, ហើយរៀនពីអ្វីគ្រប់យ៉ាងរាប់ចាប់ពីសុខភាពបន្តពូជ ដល់ឱកាសការងារ។ ពួកគេរៀបចំគម្រោងជួយខ្លួនឯង, ចូលរួមក្នុងការកៀរគរតាមសហគមន៍ដោយប្រើប្រាស់សិល្បៈ ចម្រៀង ការរាំ និងល្ខោន, ព្រមទាំងរៀនពីការបង្កើតភាពអាម៉ាស់ទៅលើជនចាប់រំលោភ ជាជាងបង្កើតភាពអាម៉ាស់លើខ្លួនឯង។



www.hesperian.org health guides

## សកម្មភាព ការសម្រេចក្ដីសុបិនរបស់អ្នក

សកម្មភាពនេះអ្នកជួយឲ្យក្រុមក្មេងស្រីជំទង់ ធ្វើការឆ្លុះបញ្ចាំងពីគោលដៅផ្ទាល់ខ្លួនរបស់ពួកគេ និងពីបំណិនជីវិតដែលពួកគេត្រូវការ។ ការឆ្លុះបញ្ចាំងពីក្ដីសុបិននិងគោលដៅផ្ទាល់ខ្លួន ធ្វើឲ្យក្មេងស្រីមានការជំរុញទឹកចិត្ត និងទទួលបានទិសដៅដែលចាំបាច់។ នៅពេលក្រុមគ្រួសារ គ្រូបង្រៀន និងសហគមន៍ លើកទឹកចិត្តដល់ក្មេងស្រីឲ្យកំណត់គោលដៅផ្ទាល់ខ្លួន រួចផ្ដល់ការគាំទ្រដែលពួកគេត្រូវការ នោះការផ្លាស់ប្ដូរក្លាយជារឿងដែលអាចធ្វើបាន។ ឧទាហរណ៍ ប្រសិនបើក្មេងស្រីម្នាក់ចូលរៀននៅសាលា នោះគាត់មានឱកាសកាន់តែច្រើនក្នុងការទទួលបានការងារធ្វើ ឬបន្តអាជីពកាន់តែខ្ពស់។ គាត់ក៏នឹងអាចធ្វើការសម្រេចចិត្តត្រឹមត្រូវក្នុងការការពារសុខភាពរបស់គាត់។

1. ប្រាប់គ្រប់គ្នាឲ្យចំណាយពេលពីរបីនាទីដើម្បីធ្វើការឆ្លុះបញ្ចាំងពីគោលដៅរបស់ពួកគេ។ អ្នកអាចផ្ដល់ក្រដាសនិងប៊ិចឲ្យក្មេងស្រីទាំងនោះសរសេរនូវគោលដៅផ្ទាល់ខ្លួនរបស់ពួកគេ ឬគូររូបភាពបញ្ជាក់។

2. សរសេរសំណួរមួយចំនួននៅលើផ្ទាំងក្រដាសធំ ឬក្ដារខៀន ដើម្បីជួយឲ្យក្មេងស្រីរិះរកគោលដៅរបស់ពួកគេ។ នេះជាសំណួរខ្លះៗដែលអ្នកអាចប្រើប្រាស់ ៖
   - តើអ្នកយល់ដឹងអ្វីខ្លះពីខ្លួនរបស់អ្នកផ្ទាល់? ចូរពិចារណាពីតម្លៃ ជំនាញ ចំណាប់អារម្មណ៍ ការទទួលខុសត្រូវ ចំណុចខ្លាំង និងចំណុចខ្សោយរបស់អ្នក។
   - តើគោលដៅរបស់អ្នកក្នុងពេលនេះមានអ្វីខ្លះ? តើគោលដៅជីវិតយូរអង្វែងរបស់អ្នកមានអ្វីខ្លះ? ឧទាហរណ៍៖ ការអប់រំ និងការបណ្ដុះបណ្ដាល, អាជីព និងការងារ, ការធ្វើដំណើរ, គោលដៅផ្ទាល់ខ្លួននិងគ្រួសារ។
   - តើនរណាខ្លះអាចជួយអ្នកឲ្យសម្រេចគោលដៅរបស់អ្នក? តើអ្នកត្រូវការជំហានអ្វីខ្លះ? តើអាចមានឧបសគ្គអ្វីខ្លះ? តើអ្នកអាចជម្នះឧបសគ្គនិងភាពមិនជឿជាក់លើខ្លួនឯងដូចម្ដេចខ្លះ?

3. បំបែកក្មេងស្រីជាក្រុមតូចៗ ហើយប្រាកដថាគ្រប់គ្នាអាចមើលសំណួរឃើញ។ ប្រាប់ក្រុមទាំងអស់ឲ្យប្រើពេលប្រហែល១០នាទីដើម្បីពិភាក្សាលើសំណួរនីមួយៗ ដោយធានាថាមនុស្សគ្រប់គ្នាក្នុងក្រុមសុទ្ធតែមានឱកាសនិយាយ។

4. នៅពេលក្រុមបានបញ្ចប់ការពិភាក្សាហើយ ចូរប្រមូលគ្រប់គ្នាមកជុំគ្នា។ សួរក្រុមទាំងអស់ឲ្យចែករំលែកនូវយោបល់របស់ពួកគេ១ឬ២ចំណុចចំពោះសំណួរនីមួយ។ បន្ទាប់មកលើកទឹកចិត្តក្មេងស្រីគ្រប់គ្នាឲ្យកំណត់ពីគោលដៅមួយរបស់ខ្លួន ព្រមទាំងជំនាញមួយចំនួនដែលចាំបាច់ដើម្បីសម្រេចគោលដៅនោះ។



# យេនឌ័រនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ

កម្មវិធីទូរទស្សន៍ កុន វីដេអូចម្រៀង និងការផ្សាយផលិតផល សុទ្ធតែប្រើប្រាស់តួនាទីយេនឌ័រនៅក្នុងសាច់រឿងរបស់ពួកគេ។ នៅពេលយើងពិចារណាពីសារលាក់កំបាំង (ឬមិនសូវកំបាំង) នៅក្នុងការផ្សាយផលិតផល, យើងអាចមើលឃើញពីការផ្សព្វផ្សាយពីយេនឌ័រ ដែលក្នុងនោះមានយេនឌ័រជាច្រើនផ្តល់ផលមិនល្អដល់សម្រាប់បុរសឬស្ត្រី។

## សកម្មភាព ពិភពនៃការផ្សព្វផ្សាយផលិតផល ៖ ស្ត្រីសិចស៊ី និងបុរសរឹងមាំ

សកម្មភាពនេះក៏ធ្វើឲ្យពួកគេមានភាពសប្បាយរីករាយ និងមានគំនិតសិល្បៈផងដែរ។ ដើម្បីរៀបចំ អ្នកត្រូវការកាសែត ឬទស្សនាវដ្តីមួយចំនួនដែលមានរូបភាពស្ត្រីនិងបុរស។ ទាំងនោះមានដូចជាទស្សនាវដ្តីសម្លៀកបំពាក់ ទស្សនាវដ្តីបុរស ឬទស្សនាវដ្តីផ្សេងៗទៀតដែលមានទំព័រផ្សាយពាណិជ្ជកម្ម។ អ្នកក៏ត្រូវការកន្ត្រៃ កាវឬស្កុត និងខ្មៅដៃឬហ្វឺត។

1. ផ្តល់ពេលឲ្យពួកគេរកមើលរូបភាពនៅក្នុងទស្សនាវដ្តី។ ប្រាប់ពួកគេឲ្យចាប់អារម្មណ៍នឹងពាណិជ្ជកម្មដែលមានរូបស្ត្រីនៅក្នុងនោះ។ ផ្តល់ឱកាសឲ្យពួកគេចែករំលែកប្រតិកម្មរបស់ខ្លួន។

2. ពិភាក្សាអំពីសារដែលពាណិជ្ជកម្មនោះប្រើប្រាស់ដើម្បីលក់ផលិតផល។ ស្រង់គំនិតទាំងឡាយដែលពួកគេមាន។ ដើម្បីជួយពួកគេឲ្យពិចារណាពីសារនៅក្នុងការផ្សាយពាណិជ្ជកម្ម ចូរសួរថាតើពាណិជ្ជកម្មនោះចង់ឲ្យយើងគិតដូចម្តេចចំពោះស្ត្រីឬបុរស។ តើឥរិយាបថណាមួយរបស់បុរសឬស្ត្រី ដែលពាណិជ្ជកម្មនោះលើកយកមកបង្ហាញ? តើពាណិជ្ជកម្មអាចធ្វើឲ្យស្ត្រីឬបុរសមានអារម្មណ៍មិនល្អចំពោះខ្លួនឯងដូចម្តេចខ្លះ?

អ្នកក៏អាចពិភាក្សាអំពីសារផ្សេងៗទៀតដែលមានឥទ្ធិពលលើតម្លៃឬឋានៈរបស់មនុស្សផងដែរ។ ឧទាហរណ៍ តើពាណិជកម្មបានប្រាប់យើងអ្វីខ្លះអំពីអ្នកក្រ អំពីអ្នកមាន និងអំពីក្រុមដែលមានស្ថានភាពសង្គមផ្សេងគ្នា?

សួរអ្នកចូលរួមថាតើពួកគេយល់ថាមានពាណិជ្ជកម្មណាមួយដែលកុហកបោកប្រាស់ដែរឬទេ។ តើជាពាណិជ្ជកម្មណាខ្លះ?

ចុងក្រោយ ប្រាប់អ្នកចូលរួមឲ្យគិតអំពីពាណិជ្ជកម្មដែលមានឥទ្ធិពលលើបញ្ហាសុខភាព។ តើពាណិជ្ជកម្មទាំងនោះព្យាយាមបញ្ចុះបញ្ចូលឲ្យមនុស្សទិញផលិតផលដែលប៉ះពាល់ដល់សុខភាពឬទេ?



**សកម្មភាព** **ពិភពនៃការផ្សព្វផ្សាយផលិតផល ៖ ស្ត្រីសិចស៊ី និងបុរសរឹងមាំ (ត)**

ប្រសិនបើគោលដៅរបស់អ្នកគឺដើម្បីជួយស្ត្រីឬមនុស្សវ័យក្មេងឲ្យយល់ពីសារនៃពាណិជ្ជកម្ម(អំពីចំណូលចិត្តផ្លូវភេទ សម្ផស្ស ឬស្ត្រីដែលសក្តិសម) អាចប៉ះពាល់ដល់សុខភាពរបស់ពួកគេ នោះអ្នកអាចផ្តោតទៅលើរូបភាពនៃដងខ្លួន រួចពិភាក្សាមើលថាតើពាណិជ្ជកម្មបានណែនាំអ្វីខ្លះអំពីសុខភាព ឬ "ដងខ្លួនដែលសក្តិសម" ដោយមើលទៅលើទម្ងន់ កម្ពស់ អាយុ ពណ៌ស្បែក និងចំណុចដទៃទៀត។

3 ឥឡូវនេះដល់ពេលដែលត្រូវច្នៃប្រឌិតថ្មី។ ក្រុមនីមួយៗអាចមានរបៀបច្រើនយ៉ាងក្នុងការច្នៃប្រឌិតលើពាណិជ្ជកម្មទាំងនេះ។ ឧទាហរណ៍ ប្រែក្លាយពាណិជ្ជកម្ម តាមរយៈការរំលេចឲ្យឃើញច្បាស់នូវ "សារលាក់កំបាំង" នៅក្នុងនោះ។ ឬថតចម្លងផ្ទាំងពាណិជ្ជកម្មណាមួយដែលបង្ហាញសារអវិជ្ជមានយ៉ាងច្បាស់ រួចធ្វើការចម្អកដល់ផ្ទាំងពាណិជ្ជកម្មនោះ។ របៀបនេះហៅថា "ការកែច្នៃរូបផ្សព្វផ្សាយ" ។ អ្នកក៏អាចរៀបចំការប្រកួតប្រជែងមួយដែលជំរុញឲ្យពួកគេបង្កើតរូបផ្សព្វផ្សាយ ឬពាណិជ្ជកម្មដែលមានលក្ខណៈវិជ្ជមាន ដែលបង្ហាញពីចំណុចខ្លាំងរបស់ស្ត្រី ឬបង្ហាញពីរបៀបថ្មីៗដែលបុរសនិងស្ត្រីគួរប្រកាន់ឥរិយាបថតាម។

**ការកែច្នៃរូបផ្សព្វផ្សាយផលិតផល** គឺប្រើប្រាស់សិល្បៈ ឬអត្ថបទដើម្បីកែប្រែអត្ថន័យរបស់រូបផ្សព្វផ្សាយផលិតផលនោះ។ វាអាចជាការបង្ហាញការពិតដ៏ខ្មៅកខ្វក់របស់ផលិតផលនោះ ឬជាការជំនួសមកវិញនូវសារថ្មីមួយ។ សារដែលគេផ្សាយនៅក្នុងពាណិជ្ជកម្ម ច្រើនតែបង្ហាញពីគំនិតមិនត្រឹមត្រូវ ឬគ្រោះថ្នាក់ ហើយយើងពិបាកនឹងកែប្រែសារនោះណាស់។ វិធីដ៏មានប្រជាប្រិយមួយក្នុងការប្រឆាំងនឹងរូបភាពដ៏គ្រោះថ្នាក់ទាំងនោះ គឺការកែច្នៃវា។ ធ្វើបែបនេះអាចទាញចំណាប់អារម្មណ៍យ៉ាងច្រើនពីប្រជាជន ហើយធ្វើឲ្យពួកគេពិចារណាឡើងវិញ។




ការកែប្រែរូបពាណិជ្ជកម្ម អាចជាការចម្អកដល់ផលិតផលនោះ ឬធ្វើការកែប្រែនូវអ្វីដែលអ្នកមើលបានទទួលពីរូបពាណិជ្ជកម្មឲ្យទៅជាអ្វីផ្សេងដែលផ្ទុយពីបំណងរបស់ពាណិជ្ជកម្ម។ វិធីដ៏សាមញ្ញមួយគឺគ្រាន់តែកាត់ក្រដាស សរសេរអក្សរបន្ថែម រួចបិតពីលើផ្ទាំងផ្សាយពាណិជ្ជកម្មនោះ ហើយថតរូបផ្ញើរឬចែករំលែក(share) តាមអ៊ីនធឺនែត។

# ការប្រើប្រាស់ច្បាប់ដើម្បីយុត្តិធម៌យេនឌ័រ

អតុល្យភាពនៃអំណាចដែលស្ត្រីជួបប្រទះក្នុងគ្រួសារនិងសហគមន៍របស់ពួកគេ មិនមែនគ្រាន់តែជារឿងផ្ទាល់រឿង ឬជាវប្បធម៌នោះទេ។ គោលនយោបាយនិងច្បាប់ខ្លះ បានផ្តល់ការគាំទ្រ និងអនុវត្តឲ្យមានវិសមភាពយេនឌ័រផងដែរ។ ឧទាហរណ៍ សហគមន៍ជាច្រើនមានច្បាប់មួយចំនួនដែលបដិសេធសិទ្ធិរបស់ស្ត្រីក្នុងការជ្រើសរើសគូរស្រករ សិទ្ធិក្នុងការលែងលះ សិទ្ធិក្នុងការគ្រប់គ្រងឬទទួលមរតកទ្រព្យសម្បត្តិ ឬសិទ្ធិក្នុងការធ្វើកិច្ចសន្យាឬរៀបចំមុខជំនួញ។ ស្ត្រីខ្លះទៀតគ្មានសូម្បីតែសិទ្ធិក្នុងការទទួល ឬបដិសេធនូវការព្យាបាលវេជ្ជសាស្ត្រទៀតផង។ (សូមមើលផ្នែក ធ្វើឲ្យប្រព័ន្ធយុត្តិធម៌ដំណើរការដើម្បីបញ្ឈប់ហិង្សា ទំព័រ 171 និងឧបសម្ព័ន្ធ កៈ ការប្រើប្រាស់ច្បាប់អន្តរជាតិក្នុងការតស៊ូមតិដើម្បីសិទ្ធិស្ត្រី ទំព័រ 300)។



*អ្នកអាចចាប់ផ្តើមពិភាក្សាពីការប្រើប្រាស់ច្បាប់ដើម្បីយុត្តិធម៌យេនឌ័រ តាមរយៈ ការពិចារណាអំពីច្បាប់បច្ចុប្បន្នដែលមិនជំរុញឲ្យមានសមភាព។ ឧទាហរណ៍ តើស្ត្រីទទួលប្រាក់កំរៃស្មើគ្នានឹងបុរសដែរឬទេចំពោះការងារដូចគ្នា? តើមានច្បាប់ដែលហាមឃាត់មិនឲ្យស្ត្រីវ័យក្មេងស្វែងរកការថែទាំវេជ្ជសាស្ត្រដែរឬទេ?*

ការដេញដោលលើច្បាប់ទាំងនេះ ការដាក់ឲ្យអនុវត្តច្បាប់ថ្មី និងការបង្កើនការយល់ដឹងអំពីច្បាប់និងគោលនយោបាយដែលលើកកម្ពស់សមភាពយេនឌ័រ, ជួនកាលត្រូវបានហៅថា យុត្តិធម៌យេនឌ័រ។ ភាគច្រើននៃកិច្ចប្រឹងប្រែងទាំងនេះ គឺផ្អែកទៅលើកិច្ចព្រមព្រៀងអន្តរជាតិនានាដែលទទួលស្គាល់សិទ្ធិស្មើភាពគ្នារបស់ស្ត្រី។

## កិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិស្មើភាពគ្នាសម្រាប់ស្ត្រីនិងបុរស

នៅពេលអង្គការសហប្រជាជាតិបង្កើតឡើងនៅឆ្នាំ១៩៤៥ ពួកគេបានបង្កើតលក្ខន្តិកៈមួយដែលទាមទារនូវ ”សិទ្ធិស្មើភាពគ្នាសម្រាប់បុរសនិងស្ត្រី។ ក្នុងពេលដែលលក្ខន្តិកៈនេះត្រូវបានសរសេរឡើង, ក្នុងចំណោម ៥១ប្រទេសដែលចូលរួម មានតែ ៣០ប្រទេសប៉ុណ្ណោះដែលមានច្បាប់អនុញ្ញាតឲ្យស្ត្រីមានសិទ្ធិដូចគ្នានឹងបុរសក្នុងការបោះឆ្នោត។ ទោះបីលក្ខន្តិកៈអង្គការសហប្រជាជនបានអំពាវនាវឲ្យមានសិទ្ធិយេនឌ័រស្មើភាពគ្នាក្តី ការរៀបចំជាអន្តរជាតិដើម្បីជជែកអំពីបញ្ហានេះ ធ្វើឡើងនៅច្រើនទសវត្សរ៍ក្រោយមកទៀតប៉ុណ្ណោះ។ ចុងក្រោយ នៅឆ្នាំ១៩៧៥ ស្ត្រីមកពីស្ទើរគ្រប់ប្រទេសទាំងអស់ក្នុងពិភពលោកបានជួបប្រជុំនៅក្នុងទីក្រុងម៉ិកស៊ិកូ ដើម្បីពិភាក្សាពីសិទ្ធិរបស់ស្ត្រី និងបានស្នើសុំធ្វើការកែប្រែដល់ច្បាប់ដែលមិនមានភាពស្មើគ្នាដែលផ្អែកលើការរំពឹងទុកក្នុងយេនឌ័រ។ កិច្ចប្រជុំលើកដំបូងនេះបានអំពាវនាវឲ្យមានការលុបបំបាត់ការរើសអើងក្នុងយេនឌ័រ ព្រមទាំងបញ្ចូលស្ត្រីទៅក្នុងផែនការអភិវឌ្ឍន៍។ កិច្ចប្រជុំបន្តបន្ទាប់ទៀតបានបង្កើតនិយាមអន្តរជាតិកាន់តែជាក់លាក់ ដូចជាការផ្តល់នូវសេវាផែនការគ្រួសារឲ្យដល់គ្រប់ស្ត្រីទាំងអស់ ការចិញ្ចឹមបីបាច់កូនស្រីឲ្យស្មើភាពគ្នា ព្រមទាំងបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងជួររដ្ឋាភិបាលនៅទូទាំងពិភពលោក។

រដ្ឋាភិបាលស្ទើរតែគ្រប់ប្រទេសបានឯកភាពជាគោលការណ៍ទៅនឹងសំណើរបស់ស្ត្រី ប៉ុន្តែក្រុមស្ត្រីក្នុងស្រុក អ្នកលើកកម្ពស់សុខភាព និងដៃគូរបស់ពួកគេ នៅតែចាំបាច់ត្រូវធ្វើការរៀបចំនិងតស៊ូជាច្រើនទៀតដើម្បីលុបបំបាត់ច្បាប់ដ៏គ្រោះថ្នាក់នានា ធ្វើការអនុវត្តនូវច្បាប់ដែលមានយុត្តិធម៌ និងផ្លាស់ប្តូរការគិតរបស់ប្រជាជនអំពីតួនាទីយេនឌ័រ និងសិទ្ធិមនុស្ស។ នៅមានកិច្ចការជាច្រើនទៀតដែលត្រូវបំពេញ!

សាច់រឿងចំនួន២ បន្ទាប់នេះ បង្ហាញពីរបៀបដែលក្រុមការងារបានរៀបចំទាមទារច្បាប់ដែលមានយុត្តិធម៌ នៅក្នុងប្រទេស២នៃទ្វីបអាហ្វ្រិក។


www.hesperian.org health guides

## ការការពារសិទ្ធិរបស់ស្ត្រីមេម៉ាយក្នុងការទទួលមរតក

នៅប្រទេសកេនយ៉ា នៅពេលប្ដីស្លាប់ ជាញឹកញាប់ នៅពេលប្ដីស្លាប់ ក្រុមគ្រួសាររបស់បុរសនោះនឹងទាមទារដីធ្លីនិងផ្ទះយកធ្វើជារបស់ខ្លួន បើទោះជាគាត់បានទុកទ្រព្យសម្បត្តិឲ្យប្រពន្ធរបស់គាត់ក៏ដោយ។ អង្គការ GROOTS (Grassroots Organizations Operating Together in Sisterhood) ផ្ដល់ការអប់រំនៅក្នុងសហគមន៍អំពីសិទ្ធិរបស់ស្ត្រីក្នុងការទទួលមរតក។ អង្គការ GROOTS ក៏បានរៀបចំជាក្រុម "ឃ្លាំមើល" ផងដែរដែលចូលរួមដោយសមាជិកសហគមន៍ ។ ក្រុមឃ្លាំមើលជាអ្នកតាមដាននិងការពារការរឹបអូសទ្រព្យសម្បត្តិពីស្ត្រីមេម៉ាយនិងកូនៗរបស់គាត់ ។

ដំបូង អង្គការ GROOTS បានរៀបចំជាក្រុមអ្នកស្ដាប់ក្នុងសហគមន៍ ដែលអ្នកចូលរួមទាំងឡាយនាំគ្នាស្ដាប់កាសែតសំឡេងរបស់ស្ត្រីដែលនិទានរឿងរ៉ាវរបស់ខ្លួនពីហេតុការណ៍ដែលពួកគាត់ត្រូវបានរឹបអូសទ្រព្យសម្បត្តិនៅពេលប្ដីរបស់គាត់ស្លាប់, និងពីទុក្ខវេទនាទាំងឡាយដែលពួកគាត់បានឆ្លងកាត់។ មនុស្សជាច្រើនបានចូលរួមជាមួយក្រុមអ្នកស្ដាប់នេះ ហើយវាបានក្លាយទៅជាក្រុមពិភាក្សាដោយមានការចូលរួមពីថ្នាក់ដឹកនាំសហគមន៍ និងចាស់ព្រឹទ្ធាចារ្យទៀតផង ។ តាមរយៈការចែករំលែករឿងរ៉ាវ និងព័ត៌មានទាក់ទងនឹងច្បាប់ ពួកគេគ្រប់គ្នាក៏បានយល់ដឹងពីសិទ្ធិរបស់ស្ត្រីក្នុងការទទួលមរតកនិងទ្រព្យសម្បត្តិ, យល់ពីមូលហេតុដែលធ្វើឲ្យមានការដណ្ដើមទ្រព្យសម្បត្តិ, និងយល់ពីមូលហេតុដែលធ្វើឲ្យស្ត្រីនិងកុមារជាច្រើនធ្លាក់ក្នុងភាពក្រីក្រ។ ការពិភាក្សាជាមួយប្រធានភូមិ និងថ្នាក់ដឹកនាំទំនៀមទម្លាប់ដទៃទៀត ជួយឲ្យពួកគាត់យល់ពីឥទ្ធិពលនៃការគាំទ្ររបស់គាត់ទៅលើស្ត្រីមេម៉ាយ និងក្រុមឃ្លាំមើលទាំងនោះ ថាវាអាចបង្ការការដណ្ដើមទ្រព្យសម្បត្តិបាន។ សហគមន៍ខ្លះបានបណ្ដុះបណ្ដាលសមាជិករបស់ខ្លួនឲ្យក្លាយជាអ្នកសម្របសម្រួលផ្លូវច្បាប់ ហើយសព្វថ្ងៃពួកគេអាចអប់រំស្ត្រីម្នាក់ៗអំពីសិទ្ធិស្របច្បាប់របស់ពួកគាត់ ។

ប៉ូលីស ថ្នាក់ដឹកនាំទំនៀមទម្លាប់ និងសហគមន៍ បានព្រមព្រៀងសហការគ្នាឃ្លាំមើលសិទ្ធិរបស់ស្ត្រីដែលបានក្លាយខ្លួនជាមេម៉ាយ។



## យុទ្ធនាការបញ្ឈប់អាពាហ៍ពិពាហ៍កុមារ នៅក្នុងប្រទេសម៉ាឡាវី

នៅប្រទេសម៉ាឡាវី ច្បាប់ចែងថាស្ត្រីអាចរៀបការនៅចន្លោះអាយុ១៥ និង១៨ឆ្នាំ ដោយមានការអនុញ្ញាតពីឪពុកម្តាយ ប៉ុន្តែមិនមានច្បាប់ដែលហាមឃាត់មិនឲ្យរៀបការនៅអាយុក្រោមនេះទេ។ ស្ទើរតែពាក់កណ្តាលនៃស្ត្រីទាំងអស់នៅប្រទេសម៉ាឡាវី បានរៀបការនៅមុនអាយុ១៨ឆ្នាំ។ នៅទីជនបទវិញ មានក្មេងស្រីខ្លះរៀបការនៅអាយុ១២ឆ្នាំទៀតផង ហើយភាគច្រើនគឺពួកគេរៀបការនៅអាយុ១៥ឆ្នាំ។ ភាគច្រើននៃស្ត្រីវ័យក្មេងទាំងនេះឈប់ទៅសាលារៀនរួចក៏មានផ្ទៃពោះឆាប់។ ប៉ុន្តែការសម្រាលកូននៅក្នុងវ័យក្មេងបែបនេះ មានគ្រោះថ្នាក់ដល់ទាំងម្តាយនិងទារក។ ជាងពាក់កណ្តាលនៃទារកដែលកើតពីម្តាយវ័យក្មេងទាំងនេះ ងាយនឹងស្លាប់ ហើយស្ត្រីវ័យក្មេងងាយនឹងមានបញ្ហាសុខភាពផ្សេងៗដូចជាការធ្លាយទ្វារមាស (មើលទំព័រ 231) ជាដើម។ ស្ថានភាពរបស់ពួកគេកាន់តែពិបាកដោយសារកង្វះការអប់រំ និងគ្មានជំនាញការងារឬកិច្ចការផ្ទះ។ បន្ទាប់ពីក្លាយជាម្តាយមក ជាញឹកញាប់ពួកគេលែងលះគ្នាយ៉ាងឆាប់រហ័ស ហើយមានស្ត្រីខ្លះក៏បានរកស៊ីផ្លូវភេទដើម្បីចិញ្ចឹមខ្លួន។

នៅឆ្នាំ២០១០ អង្គការបណ្តាញផ្តល់អំណាចដល់ស្ត្រី (GENET) បានចាប់ផ្តើមយុទ្ធនាការមួយដើម្បីធ្វើការផ្លាស់ប្តូរច្បាប់និងកំណត់អាយុ១៨ឆ្នាំ ជាអាយុស្របច្បាប់ដើម្បីរៀបការ។ ដោយសារតែព័ត៌មានស្តីពីផលប៉ះពាល់នៃការរៀបការវ័យក្មេង មិនអាចបញ្ចុះបញ្ចូលសមាជិកសភាបាន អង្គការ GENET បានសម្រេចចិត្តឲ្យសមាជិកសភា រួមទាំងប្រជាជនម៉ាឡាវីទាំងអស់ ស្តាប់នូវការរៀបរាប់ផ្ទាល់របស់ស្ត្រីវ័យក្មេងវិញម្តង។ អង្គការ GENET បានរៀបចំការប្រកួតប្រជែងសំណេរសម្រាប់ក្មេងស្រី។ ពួកគេបានទទួលសំណេរប្រមាណ ១៧៥០ ពីក្មេងស្រីដែលមានអាយុចាប់ពី ៩ ដល់ ១៧ឆ្នាំ។ ពួកគេបានជ្រើសរើសស្ត្រីទាំងនោះចំនួន ៧២នាក់ដើម្បីចូលរួមក្នុងកិច្ចពិភាក្សាមួយដោយប្រើប្រាស់សំណួរដូចខាងក្រោម ៖

"តើអ្នកយល់យ៉ាងណាចំពោះអាពាហ៍ពិពាហ៍កុមារ"?
"តើអ្នកគិតថាក្មេងស្រីអាចរៀបការនៅអាយុប៉ុន្មានដែលសមរម្យបំផុត"?
"តើស្វាមីសក្តិសមឬដែលអ្នកស្រមៃ មានលក្ខណៈបែបណាខ្លះ"?
"តើក្មេងស្រីដែលមានការអប់រំ មិនអាចធ្វើជាប្រពន្ធដ៏ល្អម្នាក់បានទេឬ"?
"តើអ្នកចង់មានជីវិតអាពាហ៍ពិពាហ៍ដូចឪពុកម្តាយរបស់អ្នកដែរឬទេ"?



បន្ទាប់មក ក្មេងស្រីចំនួន ៣៦នាក់ ចូលរួមក្នុងសិក្ខាសាលារូបភាព។ ពួកគេថតរូបគ្នាទៅវិញទៅមក រួចសរសេរអត្ថបទថ្មីៗដោយឆ្លើយនូវសំណួរដែលពួកគេបានពិភាក្សានៅក្នុងក្រុមកន្លងមក។ បច្ចុប្បន្ន រូបថតនិងអត្ថបទរបស់ពួកគេត្រូវបានរៀបចំជាសៀវភៅមួយក្បាលដែលមានចំណងជើងថា *ខ្ញុំនឹងរៀបការនៅពេលដែលខ្ញុំចង់រៀបការ!!* អង្គការ GENET បានចែកចាយសៀវភៅនេះដើម្បីបង្ហាញប្រាប់ដល់សមាជិកសភានិងថ្នាក់ដឹកនាំសហគមន៍ថា ក្មេងស្រីម៉ាឡាវីគាំទ្រទាំងស្រុងលើការកែប្រែអាយុរៀបការទៅ ១៨ឆ្នាំ និងត្រៀមខ្លួនរួចជាស្រេចដើម្បីអនុវត្តតាមច្បាប់ថ្មីនេះ។




# ការផ្លាស់ប្តូរទាមទារភាពមោះមុតនិងពេលវេលា

នៅពេលមនុស្សបានគិតពីរបៀបដែលតួនាទីយេនឌ័របង្កើតជាភាពអយុត្តិធម៌ និងបង្កគ្រោះថ្នាក់ដល់ទាំងស្ត្រីនិងបុរស, នោះពួកគេអាចចាប់ផ្តើមពិចារណាអំពីការផ្លាស់ប្តូរនានាដែលពួកគេអាចជ្រើសរើសយក។ សម្រាប់មនុស្សទូទៅ វាមានន័យថាធ្វើការផ្លាស់ប្តូរឥរិយាបថ និងការរំពឹងទុករបស់ពួកគេផ្ទាល់ ក៏ដូចជាធ្វើកិច្ចការដើម្បីផ្លាស់ប្តូរទំនៀមទម្លាប់ ស្ថានភាព និងក្បួនច្បាប់នៅក្នុងសហគមន៍របស់ពួកគេ។

វិសមភាពយេនឌ័រ គឺជាមូលហេតុឫសគល់នៃបញ្ហាសុខភាពជាច្រើនដែលត្រូវបានបង្ហាញនៅក្នុងជំពូកបន្តបន្ទាប់នៃសៀវភៅនេះ។ សកម្មភាពនិងសាច់រឿងនៅក្នុងជំពូកនីមួយៗ បង្ហាញពីវិធីផ្សេងៗជាច្រើនដែលយើងអាចជ្រើសរើសអនុវត្តនៅក្នុងកិច្ចការដើម្បីសមភាពយេនឌ័រ និងសុខភាពរបស់ស្ត្រី។